ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃជាសេនាធិការរបស់រាជរដ្ឋាភិបាល

ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

# សៀវភៅណែនាំស្តីពីការអនុវត្ត

# គោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

ព.ស.២៥៦៦ ឆ្នាំ២០២៣

Australian Aid

unicef for every child

# អារម្ភកថា

ឆ្លងកាត់បទពិសោធជាងមួយទសវត្សរ៍ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំមានសុវត្ថិភាព» និងទទួលបានលទ្ធផលគួរជាទីមោទនៈ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបន្តដាក់ចេញនូវគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»** កាលពីខែមករា ឆ្នាំ២០២១ជាថ្មី ព្រមទាំងបានពង្រីកនិងលើកកម្រិតនៃការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ពីការទទួលខុសត្រូវអនុវត្តកម្រិតក្រសួងមហាផ្ទៃទៅជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយត្រូវមានការចូលរួមអនុវត្តពីក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់និងភាគីពាក់ព័ន្ធនានា ស្របតាមតួនាទីនិងភារកិច្ចរបស់ខ្លួន។ ជាមួយគ្នានេះ លក្ខណសម្បត្តិនៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ដែលពីមុនធ្លាប់តែគ្របដណ្តប់លើការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានពង្រីកការគ្របដណ្តប់លើវិស័យមួយចំនួនថែមទៀតផងដែរ។

តាមរយៈគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ដែលបានដាក់ចេញថ្មីៗនេះ ក្រសួងមហាផ្ទៃត្រូវបានចាត់តាំងជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយ។ បន្ថែមពីលើនេះ គោលនយោបាយ ក៏បានតម្រូវឱ្យក្រសួងមហាផ្ទៃបង្កើតលេខាធិការដ្ឋាន ដើម្បីជួយដល់ក្រសួងមហាផ្ទៃក្នុងការដឹកនាំនិងការសម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងការអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព។

ដើម្បីគាំទ្រដល់ក្រសួង ស្ថាប័នអនុវត្តទាំងអស់ ក៏ដូចរដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយនេះឱ្យកាន់តែមានប្រសិទ្ធភាព និងក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃបានរៀបចំជាសៀវភៅណែនាំសម្រាប់អនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ដោយផ្អែកលើគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំពាក់ព័ន្ធ ព្រមទាំងបានធ្វើការប្រឹក្សាយោបល់ជាមួយនឹងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន។

ជារួម សៀវភៅណែនាំនេះរួមបញ្ចូលនូវខ្លឹមសារសំខាន់ៗ ដូចជាយន្តការអនុវត្ត និងតួនាទី ភារកិច្ច បញ្ជីសកម្មភាពលម្អិតប្រចាំឆ្នាំសម្រាប់អនុវត្តគោលនយោបាយ ដំណើរការនិងវិធីសាស្ត្រសម្រាប់រៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តគោលនយោបាយរបស់ស្ថាប័នអនុវត្តនានា ការត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តគោលនយោបាយ រួមបញ្ចូលទាំងការរៀបចំរបាយការណ៍និងការរៀបចំចលនាប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយរបស់ស្ថាប័នពាក់ព័ន្ធ។

ក្រសួងមហាផ្ទៃសង្ឃឹមថា សៀវភៅណែនាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»នេះនឹងមានសារប្រយោជន៍សម្រាប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្របតាមតួនាទីនិងភារកិច្ចរបស់ខ្លួន។

ក្រសួងមហាផ្ទៃក្នុងតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» សូមស្វាគមន៍នូវរាល់មតិយោបល់នានាក្នុងន័យស្ថាបនារបស់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីកែលម្អសៀវភៅណែនាំនេះឱ្យកាន់តែល្អប្រសើរ។

ថ្ងៃ................ ខែ.......... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

## មាតិកានុក្រម

ទំព័រ

អារម្ភកថា ........................................ i
បញ្ជីអក្សរកាត់ ........................................ iv
១-សេចក្តីផ្តើម ........................................ ១
១.១-និយមន័យ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ........................................ ១
១.២-ប្រវត្តិគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ........................................ ១
១.៣-មូលដ្ឋានគតិយុត្តសម្រាប់រៀបចំសៀវភៅណែនាំ. ........................................ ៣
១.៤-អំពីសៀវភៅណែនាំ........................................ ៤
២-គោលបំណងនិងគោលដៅនៃសៀវភៅណែនាំ ........................................ ៥
២.១-គោលបំណង........................................ ៥
២.២-គោលដៅ. ........................................ ៨
៣-វិសាលភាព ........................................ ៨
៤-សកម្មភាពជាអាទិភាពនិងសកម្មភាពលម្អិតសម្រាប់អនុវត្តគោលនយោបាយ ........................................ ៨
៥-យន្តការអនុវត្តនិងតួនាទី ភារកិច្ច ........................................ ១៥
៥.១-ក្រសួងមហាផ្ទៃ. ........................................ ១៥
៥.២-លេខាធិការដ្ឋាន គ.ភ.ឃ.ស. ........................................ ១៦
៥.៣-ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន. ........................................ ១៦
៥.៤-ក្រសួង ស្ថាប័ន. ........................................ ១៧
៥.៥-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........................................ ១៧
៥.៦-រដ្ឋបាលរាជធានី ខេត្ត. ........................................ ១៨
៥.៧-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត........................................ ១៨
៥.៨-ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត. ........................................ ១៩
៥.៩-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត. ........................................ ១៩
៥.១០-រដ្ឋបាលក្រុង ស្រុក ខណ្ឌ. ........................................ ១៩
៥.១១-គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ........................................ ២០
៥.១២-អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ........................................ ២០
៥.១៣-មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ. ........................................ ២០
៥.១៤-រដ្ឋបាលឃុំ សង្កាត់. ........................................ ២០
៥.១៥-ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់. ........................................ ២១
៦-ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ(ផ.ស.ថ.) ........................................ ២១
៦.១-ក្រសួង ស្ថាប័ន........................................ ២២
៦.២-ថ្នាក់រាជធានី ខេត្ត........................................ ២២

៦.៣-ថ្នាក់ក្រុង ស្រុក ខណ្ឌ ........ ២២
៦.៤-ថ្នាក់ឃុំ សង្កាត់........ ២៣
៧-ការអនុវត្តផែនការ ........ ២៣
៧.១-យន្តការអនុវត្ត. ........ ២៣
៧.២-ដំណើរការអនុវត្ត. ........ ២៣
៨-ការត្រួតពិនិត្យនិងការវាយតម្លៃ........ ២៦
៨.១-ការត្រួតពិនិត្យ........ ២៦
៨.២-ការវាយតម្លៃ........ ២៦
៨.៣-ការរៀបចំរបាយការណ៍ ........ ២៧
៨.៤-ការប្រលងប្រណាំង ........ ២៨

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ភ.ឃ.ស. | គោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» |
| ផ.ស.ថ. | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ(រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) |
| គ.ជ.គ.ម. | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |

## ១-សេចក្តីផ្តើម

### ១.១-និយមន័យ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»សំដៅទៅលើសហគមន៍ដែលមានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមល្អប្រសើរ រក្សាបាននូវបរិស្ថាន ធនធានធម្មជាតិ និងអនាម័យ ប្រជាពលរដ្ឋទទួលបានការផ្តល់សេវានានា ប្រកបដោយគុណភាព តម្លាភាព និងរស់នៅប្រកបដោយសុវត្ថិភាព ផាសុកភាព និងសុខដុមរមនា។

### ១.២-ប្រវត្តិគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

ក្នុងទសវត្សរ៍ទី៨០នៅពេលដែលប្រទេសកម្ពុជាកំពុងមានសង្គ្រាមនៅឡើយ «ចលនាប្រជាការពារ»ត្រូវបានបង្កើតឡើងតាមគោលការណ៍ស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋ ដើម្បីចូលរួមជាមួយនឹងនគរបាលក្នុងការការពារសមរភូមិក្រោយ(សហគមន៍ភូមិ-ឃុំ) និងត្រូវបានអនុវត្តប្រកបដោយជោគជ័យ និងទទួលបាននូវមេរៀនបទពិសោធល្អៗក្នុងការរក្សានិងការពារបាននូវសន្តិសុខមាតុភូមិ។

ដោយមើលឃើញច្បាស់ពីសារៈសំខាន់នៃចលនានេះ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីជូនដំណឹងលេខ៣៦៤ ស.ជ.ណ. ដើម្បីអំពាវនាវឱ្យប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់សហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច ចូលរួមការពារសន្តិសុខ និងរក្សាសណ្តាប់ធ្នាប់ក្នុងសហគមន៍នីមួយៗរបស់ខ្លួន។ បន្ទាប់មក ចលនាប្រជាការពារនេះត្រូវបានក្រសួងមហាផ្ទៃពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ សំដៅដឹកនាំ គ្រប់គ្រង និងចាត់តាំងការអនុវត្តចលនានេះឱ្យមានប្រសិទ្ធភាព រហូតដល់បានផ្តួចផ្តើមរៀបចំបង្កើតជាគោលនយោបាយ«ភូមិ-ឃុំ-មានសុវត្ថិភាព» ហើយត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គាំទ្រនិងផ្តល់អនុសាសន៍កំណត់ជាគោលការណ៍ក្នុងការកសាងផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-មានសុវត្ថិភាព» ក្នុងឱកាសមីទ្ទិញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥នាថ្ងៃបង្កើតកម្លាំងនគរបាលជាតិកម្ពុជា ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ ដើម្បីជំរុញនិងលើកកម្ពស់ចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅគ្រប់ពេលនិងគ្រប់ប្រកល្ពក នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ** នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ក្រសួងមហាផ្ទៃបានសម្រេចដាក់ចេញនូវផែនការណែនាំលេខ០២០ ផ.ក. ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-មានសុវត្ថិភាព» ក្នុងគោលបំណងកៀរគរការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដើម្បីពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ឱ្យបានល្អប្រសើរនៅគ្រប់ប្រកល្ពកនៃភូមិ-ឃុំទូទាំងប្រទេស។ ផែនការណែនាំនេះបានកំណត់នូវលក្ខណសម្បត្តិនៃ **«ភូមិ-ឃុំ-មានសុវត្ថិភាព»** ចំនួន៥ ដូចខាងក្រោម៖

- ទី១៖ គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- ទី២៖ គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- ទី៣៖ គ្មានអំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
- ទី៤៖ គ្មានក្មេងទំនើង
- ទី៥៖ គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ជាមួយគ្នានេះដែរ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីណែនាំលេខ០០២ ស.ណ.ន. ស្តីពីការបំផុសចលនាប្រលងប្រណាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-មានសុវត្ថិភាព» ។

ផ្អែកលើសមិទ្ធផលនៃការអនុវត្តលក្ខណសម្បត្តិទាំង៥ខាងលើ និងផ្អែកលើស្ថានភាពវិវត្តនៃសុវត្ថិភាពសង្គមនៅតាមមូលដ្ឋាន នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ ក្រសួងមហាផ្ទៃបានដាក់ចេញនូវផែនការណែនាំលេខ០២២ ផ.ក. ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-មានសុវត្ថិភាព» ដោយបានពិនិត្យកែសម្រួល និងបង្កើនលក្ខណសម្បត្តិនៃគោលនយោបាយ«ភូមិ-ឃុំ-មានសុវត្ថិភាព» ពីចំនួន**៥**លក្ខណសម្បត្តិទៅចំនួន៩លក្ខណសម្បត្តិ ពោលគឺបានបន្ថែមលក្ខណសម្បត្តិចំនួន**៤**លើលក្ខណសម្បត្តិទាំង**៥** ដែលបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១០។ លក្ខណសម្បត្តិទាំង**៩** រួមមានដូចខាងក្រោម៖

ទី១៖ គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

ទី២៖ គ្មានការដាំដុះ ការផលិត ការចាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់

ទី៣៖ គ្មានអំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

ទី៤៖ គ្មានក្មេងទំនើង

ទី៥៖ គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

ទី៦៖ គ្មានគ្រោះថ្នាក់ចរាចរណ៍

ទី៧៖ គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ

ទី៨៖ មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាព

ទី៩៖ គ្មានការត្រួតពិនិត្យខុសច្បាប់។

ជាមួយគ្នានេះ ក្រសួងមហាផ្ទៃ ក៏បានដាក់ចេញនូវសេចក្តីណែនាំលេខ០១៩ ស.ជ.ណ. ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការអនុវត្តគោលការណ៍វាយតម្លៃផ្តល់ចំណាត់ថ្នាក់ប្រលងប្រណាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-មានសុវត្ថិភាព»។

ក្នុងឆ្នាំ២០១៦ ក្រសួងមហាផ្ទៃបានពិនិត្យនិងកែសម្រួលលក្ខណសម្បត្តិទី៨នៃគោលនយោបាយ«ភូមិ-ឃុំមានសុវត្ថិភាព» ដោយបញ្ចូលការទប់ស្កាត់ជំងឺអេដស៍នៅតាមភូមិ-ឃុំ ស្របតាមសំណើរបស់ក្រសួងសុខាភិបាល តាមរយៈការដាក់ចេញនូវផែនការណែនាំលេខ០២១ ផ.ក. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦។ ផ្អែកលើផែនការនេះ លក្ខណសម្បត្តិទី៨នៃគោលនយោបាយ«ភូមិ-ឃុំមានសុវត្ថិភាព»ត្រូវបានកែសម្រួលដូចមានខ្លឹមសារខាងក្រោម៖

ទី៨៖ មានវិធានការបង្ការ ទប់ស្កាត់ជំងឺអេដស៍ និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

បន្ទាប់ពីបានអនុវត្តគោលនយោបាយ«ភូមិ-ឃុំមានសុវត្ថិភាព»អស់រយៈពេលជាង១០ឆ្នាំ ក្រសួងមហាផ្ទៃបានធ្វើការបូកសរុបលទ្ធផលសម្រេចបានមេរៀន បទពិសោធ និងបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងការអនុវត្តគោលនយោបាយនេះ និងបានវាយតម្លៃអំពីតម្រូវការចាំបាច់ក្នុងការពង្រឹងសុវត្ថិភាពនិងភាពសុខដុមរមនា នៅក្នុងសហគមន៍នានាតាមមូលដ្ឋានទូទាំងប្រទេស សំដៅរួមចំណែកសម្រេចគោលដៅអភិវឌ្ឍប្រទេសជាតិក្នុងរយៈពេលវែងរបស់រាជរដ្ឋាភិបាល។ ផ្អែកលើការវាយតម្លៃនេះ ក្រសួងមហាផ្ទៃបានស្នើរាជរដ្ឋាភិបាលពិនិត្យនិងដំឡើងកម្រិតគោលនយោបាយ«ភូមិ-ឃុំមានសុវត្ថិភាព»ទៅជាគោលនយោបាយ

«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»របស់រាជរដ្ឋាភិបាល ដើម្បីពង្រីកវិសាលភាពពីការទទួលខុសត្រូវអនុវត្តតែក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ទៅជាគោលនយោបាយមួយដែលមានការទទួលខុសត្រូវនិងការចូលរួមអនុវត្តពីក្រសួងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល។ ជាលទ្ធផល គោលនយោបាយរបស់រាជរដ្ឋាភិបាលលេខ០១ គនប ស្តីពី«**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**» ត្រូវបានដាក់ចេញនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១។ ផ្អែកលើគោលនយោបាយថ្មីនេះ លក្ខណសម្បត្តិរបស់គោលនយោបាយ«ភូមិ-ឃុំមានសុវត្ថិភាព»ដែលធ្លាប់តែគ្របដណ្តប់លើការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ក៏ត្រូវបានពង្រីកវិសាលភាពគ្របដណ្តប់លើវិស័យផ្សេងៗទៀត ហើយដាក់បញ្ចូលគ្នាជាលក្ខណសម្បត្តិចំនួន៧ ដូចខាងក្រោម៖

ទី១៖ ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត

ទី២៖ គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

ទី៣៖ មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍

ទី៤៖ គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង

ទី៥៖ ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាពនិងប្រសិទ្ធភាព

ទី៦៖ មានអនាម័យ មានសោភណភាពល្អ និងមានបរិស្ថានល្អ

ទី៧៖ ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។

### ១.៣-មូលដ្ឋានគតិយុត្តសម្រាប់រៀបចំសៀវភៅណែនាំ

សៀវភៅណែនាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានរៀបចំឡើងក្នុងគោលបំណងធានាការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»របស់រាជរដ្ឋាភិបាលលេខ០១ គនប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ឱ្យមានប្រសិទ្ធភាព។ សៀវភៅណែនាំនេះត្រូវបានរៀបចំដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនិងឯកសារពាក់ព័ន្ធសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- គោលនយោបាយរបស់រាជរដ្ឋាភិបាលលេខ០១ គនប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១១ ដែលពាក់ព័ន្ធនឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំកញ្ចប់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ១៤៣២ ប្រក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំបង្កើតលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ៤៤១២ ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ០១៤៩ ប្រក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងផែនការនិង

ក្រសួងមហាផ្ទៃ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបំពេញបន្ថែមលើសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

- ប្រកាសលេខ៤៣៨៩ ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សេចក្ដីណែនាំលេខ០១ ស.ណ.ន. ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្ដីពីតួនាទីភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្មដើម្បីត្រួតពិនិត្យនិងគាំទ្រកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា
- សេចក្ដីជូនដំណឹងលេខ៦៥៤ ស.ជ.ណ. ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌ គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការរបស់រដ្ឋបាលខណ្ឌ និងក្រុមការងារពាក់ព័ន្ធ
- សេចក្ដីណែនាំលេខ០១៨ ស.ណ.ន. ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ ស្ដីពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ(ចលនាប្រជាការពារ)
- សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ឆ្នាំ២០១៧
- សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ០៣ ស.ហ.វ. ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តសម្រាប់ឆ្នាំ២០២២-២០២៤
- សេចក្ដីជូនដំណឹងរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលេខ១០៧ សជណ.មយ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការយល់ព្រមជាគោលការណ៍ប្រគល់ភារកិច្ចដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំនិងដាក់ឱ្យអនុវត្តនូវគោលការណ៍ យន្តការ និងលក្ខណវិនិច្ឆ័យនានាសម្រាប់ចលនាប្រលងប្រណាំងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ
- លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត ដូចជាការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- លិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការផ្ដល់សេវាតាមវិស័យនានា ដូចជាវិស័យសុខាភិបាល អប់រំ គាំពារសង្គម ទឹកស្អាតនិងអនាម័យ ដឹកជញ្ជូន អគ្គិសនី និងសេវាសាធារណៈ ជាដើម។

**១.៤-អំពីសៀវភៅណែនាំ**

ដើម្បីធានាការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ប្រកបដោយប្រសិទ្ធភាព ក៏ដូចជាដើម្បីកសាង«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ស្របតាមនិយមន័យខាងលើ ចាំបាច់ត្រូវមានសៀវភៅណែនាំមួយច្បាស់លាស់សម្រាប់ណែនាំនិងតម្រង់ទិសស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការចូលរួមនិងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ប្រកបដោយប្រសិទ្ធភាព ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ។ ក.៥

សៀវភៅណែនាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ចែកចេញជា៨ចំណុចសំខាន់ៗ រួមមាន៖

១- សេចក្តីផ្តើមបរិយាយអំពីនិយមន័យ ប្រវត្តិ មូលដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងរចនាសម្ពន្ធសៀវភៅណែនាំ

២- រៀបរាប់អំពីគោលបំណងនៃ **គ.ភ.ឃ.ស.** រួមបញ្ចូលសូចនាករសំខាន់ៗ និងគោលដៅនៃសៀវភៅណែនាំ

៣- កំណត់អំពីវិសាលភាពនៃការអនុវត្ត **គ.ភ.ឃ.ស.**

៤- រៀបរាប់សកម្មភាពជាអាទិភាព និងសកម្មភាពលម្អិតសម្រាប់អនុវត្តគោលនយោបាយ

៥- រៀបរាប់អំពីយន្តការអនុវត្ត តួនាទី ភារកិច្ចរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការអនុវត្ត **គ.ភ.ឃ.ស.**

៦- បរិយាយអំពីដំណើរការកសាងផែនការសកម្មភាពនិងថវិកាសម្រាប់អនុវត្តគោលនយោបាយ

៧- រៀបរាប់អំពីការអនុវត្តផែនការនិងថវិកាស្តីពីការអនុវត្ត **គ.ភ.ឃ.ស.**

៨- បរិយាយដំណើរការនិងនីតិវិធីសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃ រួមបញ្ចូលទាំងការរៀបចំចលនាប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

## ២-គោលបំណងនិងគោលដៅនៃសៀវភៅណែនាំ

### ២.១-គោលបំណង

ស្របជាមួយនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»សៀវភៅណែនាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»មានគោលបំណងជំរុញនិងពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ឱ្យមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព សំដៅកសាងនិងពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីគ្រោះមហន្តរាយនិងជំងឺឆ្លងរាតត្បាត នៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ ព្រមទាំងរួមចំណែកអនុវត្តដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

ការសម្រេចបាននូវគោលបំណងខាងលើនេះត្រូវបានវាស់វែង តាមរយៈសូចនាករសមិទ្ធផលសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងវិស័យនីមួយៗ ដូចមានជាឧទាហរណ៍ខាងក្រោម៖

**សេវាសាធារណៈ៖**

- ភាពក្រីក្រនិងភាពអត់ឃ្លាន
  - ភាគរយប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ
  - ភាគរយប្រជាជនរស់នៅក្នុងភាពអត់ឃ្លាន។
- ការអប់រំ
  - ភាគរយកុមារកំពុងសិក្សា(កម្រិតមត្តេយ្យសិក្សា កម្រិតបឋមសិក្សា កម្រិតអនុវិទ្យាល័យ)
  - ភាគរយកុមារដែលត្រូវបានជួយគាំទ្រដើម្បីទទួលបានការអប់រំ(កុមារមានពិការភាព កុមារក្រីក្រ និងក្រុមជនងាយរងគ្រោះនានា)

- ភាគរយសាលារៀនដែលមានហេដ្ឋារចនាសម្ពន្ធ ទឹកស្អាត មានលក្ខណៈសមស្របចំពោះសិស្សមានពិការភាព។

➢ សុខាភិបាល
- ភាគរយកុមារដែលទទួលបានការចាក់វ៉ាក់សាំងការពារគ្រប់ចំនួនតាមអាយុកំណត់
- ភាគរយកុមារដែលទទួលបានការព្យាបាលជំងឺកង្វះជីវជាតិ
- ភាគរយស្ត្រីដែលសម្រាលកូននៅមូលដ្ឋានសុខាភិបាលនានា
- អត្រាស្លាប់របស់កុមារក្នុង១.០០០កំណើត។

➢ ទឹកស្អាតនិងអនាម័យ
- ភាគរយគ្រួសារដែលមានបង្គន់អនាម័យ
- ភាគរយគ្រួសារដែលមានប្រព័ន្ធទឹកស្អាត
- ភាគរយភូមិដែលមានប្រព័ន្ធលូបង្ហូរទឹកកខ្វក់និងចាក់ចោលកាកសំណល់។

➢ កិច្ចគាំពារសង្គម
- ភាគរយប្រជាជនងាយរងគ្រោះដែលទទួលបានការផ្ទេរសាច់ប្រាក់
- ចំនួនឬភាគរយកុមារងាយរងគ្រោះដែលទទួលបានការថែទាំនៅក្នុងសហគមន៍
- ចំនួនឬភាគរយចាស់ជរាដែលទទួលបានការថែទាំនៅក្នុងសហគមន៍។

➢ ការដឹកជញ្ជូន
- ប្រវែងផ្លូវដែលទទួលបានការថែទាំជាប្រចាំ
- ចំនួនមធ្យោបាយដឹកជញ្ជូន
- ចំនួនគ្រួសារងាយរងគ្រោះដែលទទួលបានមធ្យោបាយដឹកជញ្ជូន ដើម្បីទទួលបានសេវា។

➢ អគ្គិសនី
- ចំនួនគ្រួសារដែលទទួលបានសេវាអគ្គិសនីប្រើប្រាស់(សេវារដ្ឋឬសេវាឯកជន)
- ចំនួនគ្រួសារងាយរងគ្រោះដែលទទួលបានសេវាអគ្គិសនីប្រើប្រាស់។

➢ ការសម្អាតមីន
- ចំនួនជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម
- ទំហំផ្ទៃដីដែលបានបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

➢ សេវាពាក់ព័ន្ធនឹងការលើកកម្ពស់ជីវភាព
- ភាគរយគ្រួសារដែលទទួលបានទុន(វិស័យកសិកម្ម...) ដើម្បីលើកកម្ពស់ជីវភាព
- ភាគរយប្រជាពលរដ្ឋ ដូចជាយុវជន ជនមានពិការភាព ស្ត្រីជាមេគ្រួសារ.........ដែលទទួលបានការអប់រំអំពីជំនាញពាក់ព័ន្ធនឹងការលើកកម្ពស់ជីវភាព
- ចំនួនប្រជាពលរដ្ឋដែលទទួលបានការគាំទ្រ ដើម្បីចាប់ផ្តើមមុខរបរខ្នាតតូច។

➢ យន្តការច្រកចេញចូលតែមួយ
- ភាគរយកុមារអាយុក្រោម៥ឆ្នាំដែលមានសំបុត្រកំណើត
- ចំនួនការចុះបញ្ជីអត្រានុកូលដ្ឋាន
- ចំនួនលិខិតអនុញ្ញាតដែលបានចេញ។

**បទល្មើស៖**

- ចំនួនករណីបទល្មើស
- ចំនួនករណីចោរកម្ម
- ចំនួនករណីប្លន់។

**សណ្តាប់ធ្នាប់សាធារណៈ៖**

- ចំនួនឬភាគរយករណីគ្រោះថ្នាក់ចរាចរណ៍
- ចំនួនប្រជាពលរដ្ឋស្លាប់ក្នុងមួយថ្ងៃ ដោយសារគ្រោះថ្នាក់ចរាចរណ៍។

**អំពើអនាចារ ការជួញដូរ និងអំពើហិង្សា៖**

- ចំនួនឬភាគរយអនាចារគ្រប់ប្រភេទ
- ចំនួនឬភាគរយការជួញដូរមនុស្សគ្រប់ប្រភេទ រួមទាំងការជួញដូរកុមារ
- ចំនួនឬភាគរយករណីអំពើហិង្សាគ្រប់ប្រភេទ
- ចំនួនជនរងគ្រោះដែលបានសង្គ្រោះពីអំពើអនាចារ ការជួញដូរ និងអំពើហិង្សា។

**វិវាទនៅមូលដ្ឋាន៖**

- ចំនួនវិវាទនៅមូលដ្ឋាន
- ចំនួនឬភាគរយវិវាទនៅមូលដ្ឋានដែលបានសម្រុះសម្រួលនិងដោះស្រាយក្រៅប្រព័ន្ធតុលាការ។

**អនាម័យ សោភណភាព និងបរិស្ថាន៖**

- ភាគរយគ្រួសារដែលទទួលបានការផ្គត់ផ្គង់ទឹកស្អាត
- ភាគរយគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់
- ភាគរយគ្រួសារដែលទទួលបានសេវាប្រព័ន្ធលូបង្ហូរទឹកកខ្វក់
- ភាគរយគ្រួសារដែលទទួលបានសេវាកម្មប្រមូលសំរាម
- ចំនួនឬភាគរយការកាប់បំផ្លាញព្រៃឈើនិងការទន្ទ្រានព្រៃឈើ
- ចំនួនសួនសាធារណៈដែលបានបង្កើត
- ចំនួនឬភាគរយដើមឈើដែលបានដាំតាមដងផ្លូវ ទីវត្តអារាម សាលារៀន...
- ចំនួនសហគមន៍ព្រៃឈើដែលបានបង្កើត
- ចំនួនឬភាគរយឃុំ សង្កាត់ដែលបានវិភាជថវិកាសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុ
- ភាគរយគម្រោង សកម្មភាពអភិវឌ្ឍមូលដ្ឋាន រួមបញ្ចូលទាំងគម្រោង សកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ជូនប្រជាពលរដ្ឋ។

**គ្រោះមហន្តរាយនិងជំងឺឆ្លងរាតត្បាត៖**

- ចំនួនឬភាគរយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយនិងជំងឺឆ្លង
- ចំនួនឬភាគរយប្រជាពលរដ្ឋឬគ្រួសារដែលទទួលបានសេវាផ្តល់ដំណឹងជាមុន អំពីហានិភ័យ
- ចំនួនឬភាគរយគម្រោង សកម្មភាពអភិវឌ្ឍមូលដ្ឋាន រួមបញ្ចូលទាំងគម្រោងនិងសកម្មភាពពាក់ព័ន្ធនឹងគ្រោះមហន្តរាយ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ជូនប្រជាពលរដ្ឋ។

ក្រៅពីសូចនាករខាងលើនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចពិនិត្យ កែសម្រួល និងបន្ថែមសូចនាករផ្សេងទៀត ដែលស្របទៅនឹងតួនាទីនិងភារកិច្ចរបស់ខ្លួន និងឯកសារគោលនយោបាយជាតិ ដូចជាយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

២.២-គោលដៅ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដោយមានគោលដៅជាក់លាក់ ដូចខាងក្រោម៖

- កំណត់វិសាលភាពនៃការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- បង្ហាញនិងណែនាំអំពីសកម្មភាពជាអាទិភាពនានាដែលត្រូវអនុវត្តដើម្បីសម្រេចបានលក្ខណសម្បត្តិរបស់«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»នីមួយៗ
- កំណត់យន្តការ តួនាទី និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- ណែនាំអំពីកិច្ចដំណើរការនិងវិធីសាស្ត្រសម្រាប់អនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រួមមាន៖
  + ការរៀបចំផែនការសកម្មភាពនិងថវិកា
  + ការអនុវត្តផែនការ ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍
  + ការវាយតម្លៃ
  + ការរៀបចំចលនាប្រលងប្រណាំង។

**៣-វិសាលភាព**

សៀវភៅណែនាំនេះមានវិសាលភាពគ្របដណ្តប់លើវិស័យនានាដែលពាក់ព័ន្ធនឹងលក្ខណសម្បត្តិទាំង៧នៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ហើយត្រូវអនុវត្តដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបេសកកម្ម តួនាទី និងភារកិច្ចជាក់លាក់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលបានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

***៤-សកម្មភាពជាអាទិភាពនិងសកម្មភាពលម្អិតសម្រាប់អនុវត្តគោលនយោបាយ***

ដើម្បីធានាការសម្រេចបាននូវគោលបំណងខាងលើនិងលក្ខណសម្បត្តិទាំង៧របស់«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក៏ដូចជាការរួមចំណែកក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការកំណត់និងការអនុវត្តលើសកម្មភាពជាអាទិភាពនិងសកម្មភាពលម្អិតនានា ដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រកបដោយភាពជាម្ចាស់ ការទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់ ស្របតាមបេសកកម្ម តួនាទី និងភារកិច្ចរបស់ខ្លួន។ សកម្មភាពជាអាទិភាពនិងសកម្មភាពលម្អិតទាំងនោះ មានរៀបរាប់តាមលក្ខណសម្បត្តិក្នុងតារាងខាងក្រោម។ ក្រៅពីសកម្មភាពជាអាទិភាពទាំងនេះ ស្ថាប័នអនុវត្តទាំងអស់អាចពិនិត្យ កែសម្រួល និងបន្ថែមសកម្មភាពលម្អិតផ្សេងទៀត ដែលយល់ថាមានភាពចាំបាច់។

| លក្ខណសម្បត្តិ | សកម្មភាពជាអាទិភាព | សកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ |
|---|---|---|
| **ទី១<br>សេវាសាធារណៈ** | ➢ ការលើកកម្ពស់ក្នុងការផ្តល់សេវាសាធារណៈចាំបាច់ និងជាមូលដ្ឋានៈ<br>• ភាពក្រីក្រនិងភាពអត់ឃ្លាន<br>• ការអប់រំ<br>• សុខភាពនិងសុខុមាលភាព<br>• កិច្ចគាំពារសង្គម<br>• គមនាគមន៍<br>• ទឹកស្អាតនិងអនាម័យ<br>• អគ្គិសនីនិងថាមពលស្អាត<br>• ការសម្អាតមីន<br>• សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងជីវភាព។<br>➢ ពង្រឹងនិងពង្រីកការផ្តល់សេវានានាតាមរយៈយន្តការច្រកចេញចូលតែមួយ។ | ➢ រៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងគម្រោងអភិវឌ្ឍមូលដ្ឋាន ស្តីពីការអប់រំ សុខាភិបាល ទឹកស្អាត និងអនាម័យ កិច្ចគាំពារសង្គម ការដឹកជញ្ជូន អគ្គិសនី មីន និងសំណល់មិនទាន់ផ្ទុះពីសង្គ្រាម និងគមនាគមន៍...<br>➢ រៀបចំវគ្គបណ្តុះបណ្តាល អប់រំ និងផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការអប់រំ សុខាភិបាល ទឹកស្អាត និងអនាម័យ កិច្ចគាំពារសង្គម ការដឹកជញ្ជូន អគ្គិសនី មីន សំណល់មិនទាន់ផ្ទុះពីសង្គ្រាម និងគមនាគមន៍....<br>➢ រៀបចំនិងអនុវត្តគម្រោង សកម្មភាពពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈចាំបាច់នានាក្នុងវិស័យអប់រំ សុខាភិបាល ទឹកស្អាត និងអនាម័យ កិច្ចគាំពារសង្គម គមនាគមន៍ អគ្គិសនី មីន និងសំណល់មិនទាន់ផ្ទុះពីសង្គ្រាម និងការផ្តល់សេវាសាធារណៈផ្សេងទៀត<br>➢ អនុវត្តគម្រោង សកម្មភាព និងអន្តរាគមន៍ពាក់ព័ន្ធនឹងការជួសជុលនិងការសាងសង់ហេដ្ឋារចនាសម្ពន្ធក្នុងវិស័យអប់រំ សុខាភិបាល ទឹកស្អាត កិច្ចគាំពារសង្គម ការដឹកជញ្ជូន អគ្គិសនី មីន និងសំណល់មិនទាន់ផ្ទុះពីសង្គ្រាម និងវិស័យពាក់ព័ន្ធ<br>➢ លើកកម្ពស់ការផ្តល់សេវានានា តាមរយៈយន្តការច្រកចេញចូលតែមួយ<br>➢ រៀបចំនិងអនុវត្តការបណ្តុះបណ្តាល ការអប់រំ ការផ្សព្វផ្សាយអំពីការផ្តល់សេវា តាមរយៈយន្តការច្រកចេញចូលតែមួយ<br>➢ រៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានពាក់ព័ន្ធនឹងយន្តការច្រកចេញចូលតែមួយ<br>➢ រៀបចំនិងដាក់ឱ្យអនុវត្តនូវរចនាសម្ពន្ធនិងប្រព័ន្ធនៃយន្តការច្រកចេញចូលតែមួយ |

| លក្ខណសម្បត្តិ | សកម្មភាពជាអាទិភាព | សកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ |
| --- | --- | --- |
| | | ➢ ចុះត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| **ទី២ បទល្មើស** | ➢ ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងបញ្ជាដឹកនាំការអនុវត្តផែនការប្រយុទ្ធប្រឆាំងបទល្មើស<br>➢ លើកកម្ពស់សមត្ថភាពនិងជំនាញរបស់មន្ត្រីនគរបាលយុត្តិធម៌និងមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ក្នុងការស្រាវជ្រាវការស៊ើបអង្កេត និងការជំរុញសកម្មភាពតាមចាប់មុខសញ្ញា និងការអនុវត្តដីកា<br>➢ តាមដាន ត្រួតពិនិត្យ និងដឹកនាំតម្រង់ទិសដល់នគរបាលប៉ុស្តិ៍រដ្ឋបាល ក្នុងការអនុវត្តការងារនគរបាល និងសហគមន៍<br>➢ ការយកចិត្តទុកដាក់ក្នុងការគាំទ្រប៉ុស្តិ៍នគរបាលរដ្ឋបាលទាំងផ្នែកស្មារតី សមត្ថភាព ឧបករណ៍ សម្ភារៈ ដើម្បីពង្រឹងលទ្ធភាពក្នុងការគ្រប់គ្រងស្ថានការណ៍សន្តិសុខ សណ្តាប់ធ្នាប់ ក្នុងឃុំ សង្កាត់<br>➢ ការពង្រឹងប្រជាការពារដើម្បីចូលរួមក្នុងការរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់នៅមូលដ្ឋាន និងការលើកកម្ពស់កិច្ចសហការជាមួយនឹងកម្លាំងសមត្ថកិច្ចពាក់ព័ន្ធ<br>➢ រៀបចំផែនការបង្ការ ទប់ស្កាត់ បង្ក្រាបសកម្មភាពលួចនាំចូលសារធាតុញៀនខុសច្បាប់គ្រប់ប្រភេទ<br>➢ លើកកម្ពស់ការបង្ការនិងការព្យាបាលចំពោះអ្នកសេពសារធាតុញៀន<br>➢ ការអនុវត្តវិធានការរដ្ឋបាលនានា ក្នុងការស្រាវជ្រាវ ការតាមដាន ការត្រួតពិនិត្យការលួចជួញដូរ និងការប្រើប្រាស់សារធាតុញៀនខុសច្បាប់គ្រប់ប្រភេទ<br>➢ ការអប់រំនិងការផ្សព្វផ្សាយនៅតាមសហគមន៍និងសាលារៀន និងបញ្ជ្រាបការអប់រំនៅ | ➢ ពិនិត្យកែសម្រួលបង្កើតនិងដាក់ឱ្យដំណើរការនូវយន្តការពាក់ព័ន្ធនឹងការតាមដានការត្រួតពិនិត្យ និងការបញ្ជាដឹកនាំការអនុវត្តផែនការប្រយុទ្ធប្រឆាំងបទល្មើស<br>➢ រៀបចំនិងអនុវត្តផែនការស្តីពីការបង្ការការទប់ស្កាត់ និងការបង្ក្រាបបទល្មើសគ្រប់ប្រភេទ<br>➢ រៀបចំការបណ្តុះបណ្តាល ការអប់រំ និងការផ្សព្វផ្សាយអំពីបទល្មើសនានា ព្រមទាំងការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសទាំងនោះ<br>➢ រៀបចំនិងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសគ្រប់ប្រភេទ<br>➢ ស្រាវជ្រាវដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ<br>➢ សម្របសម្រួលនិងសហការជាមួយនឹងដៃគូពាក់ព័ន្ធ ក្នុងការបង្ការនិងការទប់ស្កាត់លើបទល្មើស<br>➢ ជ្រើសរើសនិងបង្កើតកម្លាំងប្រជាការពាររួមទាំងការអភិវឌ្ឍសមត្ថភាពនិងជំនាញនានាក្នុងការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួន<br>➢ បំផុសមហាជនឱ្យចូលរួមក្នុងចលនាប្រជាការពារ និងធ្វើបច្ចុប្បន្នភាពជាប្រចាំដើម្បីគ្រប់គ្រងនិងដឹកនាំប្រកបដោយប្រសិទ្ធភាព<br>➢ ត្រួតពិនិត្យ តាមដាន វាយតម្លៃ និងគាំទ្រការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសគ្រប់ប្រភេទ។ |

| លក្ខណសម្បត្តិ | សកម្មភាពជាអាទិភាព | សកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ |
|---|---|---|
| | តាមពិធីផ្សេងៗ អំពីគ្រោះមហន្តរាយ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន<br>➢ ស្រាវជ្រាវនិងបង្ក្រាបការជាំដុះសារធាតុញៀនគ្រប់ប្រភេទ<br>➢ ការផ្លាស់ប្តូរព័ត៌មានជាមួយនឹងដៃគូជាតិ និងអន្តរជាតិ សំដៅបង្ការ ទប់ស្កាត់ និងសហការស្រាវជ្រាវ ដើម្បីកាត់ផ្តាច់ខ្សែរយៈ និងតាមចាប់មេខ្លោងមកផ្តន្ទាទោសតាមច្បាប់។ | |
| **ទី៣ សណ្តាប់ធ្នាប់សាធារណៈ** | ➢ អប់រំនិងផ្សព្វផ្សាយអំពីច្បាប់ និងផលប៉ះពាល់នានាដែលបណ្តាលមកពីការមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមរយៈវិធីសាស្ត្រផ្សព្វផ្សាយនិងអប់រំគ្រប់រូបភាព<br>➢ រៀបចំសណ្តាប់ធ្នាប់នៅតាមតំបន់ទីផ្សារ ទីប្រជុំជន សាលារៀន និងតំបន់ស្មុគស្មាញនានា។ | ➢ រៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអប់រំនិងការផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ តាមរយៈវិធីសាស្ត្រនិងមធ្យោបាយផ្សព្វផ្សាយនិងអប់រំគ្រប់រូបភាព<br>➢ រៀបចំនិងអនុវត្តការអប់រំផ្សព្វផ្សាយអំពីច្បាប់ និងផលប៉ះពាល់នានាដែលបណ្តាលមកពីការមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមរយៈវិធីសាស្ត្រផ្សព្វផ្សាយនិងអប់រំគ្រប់រូបភាព<br>➢ រៀបចំនិងអនុវត្តគម្រោងឬសកម្មភាពពាក់ព័ន្ធនឹងការអប់រំផ្សព្វផ្សាយអំពីច្បាប់ និងផលប៉ះពាល់នានាដែលបណ្តាលមកពីការមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក<br>➢ រៀបចំសណ្តាប់ធ្នាប់នៅតាមតំបន់ផ្សារ ទីប្រជុំជនសាលារៀន និងតំបន់ស្មុគស្មាញនានា<br>➢ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រការលើកកម្ពស់សណ្តាប់ធ្នាប់សាធារណៈ។ |
| **ទី៤ អំពើអនាចារ ការជួញដូរមនុស្ស អំពើហិង្សា ក្មេងទំនើង** | ➢ បង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់ទាំងផ្នែកបច្ចេកទេស ប្រតិបត្តិការ និងនីតិវិធីស្រាវជ្រាវនិងស៊ើបអង្កេតនានា<br>➢ សកម្មភាពស្រាវជ្រាវនិងស៊ើបអង្កេតរកមេខ្លោងពាក់ព័ន្ធ<br>➢ កិច្ចសហការជាមួយនឹងស្ថាប័ននិងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជំរុញសកម្មភាពផ្សព្វផ្សាយអប់រំ សង្គ្រោះ និងស្តារនីតិសម្បទាជនរងគ្រោះ | ➢ រៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានសេចក្តីណែនាំ និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងអំពើអនាចារ ការជួញដូរមនុស្ស កិច្ចការពារកុមារ អំពើហិង្សាក្នុងគ្រួសារ ក្មេងទំនើង សិទ្ធិសេរីភាពជាមូលដ្ឋាន សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>➢ រៀបចំនិងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការបណ្តុះបណ្តាលការអប់រំ និងការផ្សព្វផ្សាយអំពើអនាចារ ការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ ក្មេងទំនើង សិទ្ធិសេរីភាពជា |

| លក្ខណសម្បត្តិ | សកម្មភាពជាអាទិភាព | សកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ |
|---|---|---|
| | ➢ គ្រប់គ្រងនិងស្រាវជ្រាវតាមទីតាំងអាជីវកម្ម និងសេវាកម្មដែលលួចប្រព្រឹត្តអំពើអនាចារ និងការជួញដូរផ្លូវភេទ<br>➢ ពង្រឹងយន្តការសហការជាមួយនឹងដៃគូជាតិនិងអន្តរជាតិ ក្នុងការផ្លាស់ប្តូរព័ត៌មាន<br>➢ រៀបចំវេទិកាផ្សព្វផ្សាយអំពីគុណធម៌ សីលធម៌ វប្បធម៌ និងច្បាប់ពាក់ព័ន្ធ សំដៅកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសកម្មភាពក្មេងទំនើង<br>➢ ធានាការទទួលបានជាសាធារណៈនូវព័ត៌មាន និងការការពារសិទ្ធិសេរីភាពជាមូលដ្ឋាន។ | មូលដ្ឋាន សមភាពយេនឌ័រ សមធម៌ និងបរិយាបន្នសង្គម<br>➢ រៀបចំនិងអនុវត្តយន្តការពាក់ព័ន្ធនឹងការបង្ការ ការទប់ស្កាត់ ការសង្គ្រោះ និងការបង្ក្រាបអំពើអនាចារ ការជួញដូរមនុស្ស ក្មេងទំនើង អំពើហិង្សាក្នុងគ្រួសារ សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>➢ រៀបចំនិងអនុវត្តគម្រោងសកម្មភាពពាក់ព័ន្ធនឹងការស្តារនីតិសម្បទាជនរងគ្រោះដោយសារអំពើអនាចារ ការជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ<br>➢ រៀបចំនិងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការស្រាវជ្រាវនិងការស៊ើបអង្កេតចំពោះអំពើអនាចារ ការជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ<br>➢ អនុវត្តការស្រាវជ្រាវនិងការសង្គ្រោះពលរដ្ឋខ្មែរនៅក្រៅប្រទេសដែលរងគ្រោះដោយសារការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការជួញដូរផ្លូវភេទ<br>➢ រៀបចំនិងគ្រប់គ្រងបញ្ជីក្មេងទំនើង ដើម្បីតាមដាន ទប់ស្កាត់ និងបង្ក្រាបសកម្មភាពទំនើង ឱ្យបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព<br>➢ ចុះតាមដាន ត្រួតពិនិត្យ និងគាំទ្រការបង្ការ ការទប់ស្កាត់ ការសង្គ្រោះ និងការបង្ក្រាបអំពើអនាចារ ការជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ។ |
| **ទី៥<br>វិវាទនៅមូលដ្ឋាន** | ➢ បង្កើនសមត្ថភាពចំណេះដឹងនិងជំនាញដល់អ្នកទទួលសិទ្ធិក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ អំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ<br>➢ ពង្រឹងអព្យាក្រឹត្យភាពនិងវិជ្ជាជីវៈរបស់អ្នកសម្របសម្រួល | ➢ រៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ<br>➢ រៀបចំនិងអនុវត្តការបណ្តុះបណ្តាល ការអប់រំ និងការផ្សព្វផ្សាយអំពីច្បាប់និងលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងសិទ្ធិ ការដោះស្រាយវិវាទ |

| លក្ខណាសម្បត្តិ | សកម្មភាពជាអាទិភាព | សកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ |
| --- | --- | --- |
| | ➢ រៀបចំកំណត់ហេតុនៃការដោះស្រាយនិងជូនព័ត៌មានអំពីលទ្ធផលនៃដំណោះស្រាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅ<br>➢ លើកកម្ពស់ការប្រឆាំងនឹងអំពើពុករលួយ។ | ក្រៅប្រព័ន្ធតុលាការ និងការប្រឆាំងនឹងអំពើពុករលួយ<br>➢ រៀបចំនិងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការរៀបចំនិងអភិវឌ្ឍស្ថាប័ន ឱ្យមានប្រសិទ្ធភាព និងគណនេយ្យភាព<br>➢ រៀបចំនិងដាក់ឱ្យដំណើរការនូវយន្តការនានាដើម្បីប្រឆាំងនឹងអំពើពុករលួយ<br>➢ អភិវឌ្ឍសមត្ថភាពអ្នកសម្របសម្រួលនិងភាគីពាក់ព័ន្ធ អំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ<br>➢ សម្របសម្រួលនិងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ<br>➢ ថែរក្សាទុកទិន្នន័យនិងព័ត៌មានពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ<br>➢ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងការអនុវត្តយន្តការនានា ដើម្បីប្រឆាំងនឹងអំពើពុករលួយ។ |
| **ទី៦ អនាម័យ សោភណភាព បរិស្ថាន** | ➢ តាមដាននិងត្រួតពិនិត្យនៅទីតាំងសាធារណៈអំពីការគ្រប់គ្រងអនាម័យនិងបរិស្ថាន<br>➢ ការពារ ទប់ស្កាត់ និងឆ្លើយតបចំពោះគ្រោះថ្នាក់នៃការពុលអាហារនិងភេសជ្ជៈនានាដោយសារជាតុគីមី<br>➢ រៀបចំផែនការបង្ការនិងទប់ស្កាត់ការកាប់បំផ្លាញនិងទន្ទ្រានទីតាំងព្រៃឈើក្នុងសហគមន៍<br>➢ លើកកម្ពស់ការកាត់បន្ថយផលប៉ះពាល់បរិស្ថាននៅទីក្រុង<br>➢ លើកកម្ពស់បរិស្ថានបៃតង និងបរិស្ថានសាធារណៈប្រកបដោយសុវត្ថិភាព និងបរិយាបន្ន។ | ➢ រៀបចំនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាន សេចក្តីណែនាំ និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការលើកកម្ពស់អនាម័យ សោភណភាពបរិស្ថាន ការប្រែប្រួលអាកាសធាតុ គ្រោះថ្នាក់ដោយសារការពុលអាហារ និងភេសជ្ជៈដោយសារជាតុគីមី<br>➢ រៀបចំនិងអនុវត្តការបណ្តុះបណ្តាល ការអប់រំ និងការផ្សព្វផ្សាយអំពីអនាម័យ សោភណភាពបរិស្ថានបៃតង ការប្រែប្រួលអាកាសធាតុ និងគ្រោះថ្នាក់ដោយសារការពុលអាហារ និងភេសជ្ជៈដោយសារជាតុគីមី<br>➢ រៀបចំនិងអនុវត្តគម្រោងនិងសកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់អនាម័យ |

| លក្ខណសម្បត្តិ | សកម្មភាពជាអាទិភាព | សកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ |
|---|---|---|
| | | សោភណភាព បរិស្ថានបៃតង ផលប៉ះពាល់បរិស្ថាន និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ<br>➢ រៀបចំនិងអនុវត្តគម្រោងនិងសកម្មភាពពាក់ព័ន្ធនឹងការការពារ ការទប់ស្កាត់ និងការឆ្លើយតបចំពោះគ្រោះថ្នាក់ដោយសារការពុលអាហារ និងភេសជ្ជៈដោយសារជាតុគីមី<br>➢ រៀបចំនិងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការការពារ ការទប់ស្កាត់ ការកាប់បំផ្លាញ និងការទន្ទ្រានទីតាំងព្រៃឈើក្នុងសហគមន៍ ការការពារប្រភពទឹកនិងដីមានផលិតភាពនានា<br>➢ រៀបចំនិងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាប្រឈមនានាបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងកសាងសហគមន៍ដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ<br>➢ រៀបចំនិងអនុវត្តសកម្មភាពទប់ស្កាត់និងឆ្លើយតបចំពោះគ្រោះថ្នាក់បណ្តាលមកពីការពុលអាហារ និងភេសជ្ជៈនានា ព្រមទាំងការកាត់បន្ថយជំងឺ និងការស្លាប់ដោយសារជាតុគីមីនិងសារជាតុពុលផ្សេងៗ<br>➢ រៀបចំផែនការបង្ការនិងទប់ស្កាត់ការកាប់បំផ្លាញ និងការទន្ទ្រានទីតាំងព្រៃឈើក្នុងសហគមន៍<br>➢ រៀបចំនិងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងការគាំទ្រលើការគ្រប់គ្រងអនាម័យ សោភណភាពបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះថ្នាក់នានាដោយសារការពុលអាហារ និងភេសជ្ជៈដោយសារជាតុគីមី។ |
| **ទី៧ គ្រោះមហន្តរាយ** | ➢ រៀបចំផែនការទុកជាមុន អំពីការសង្គ្រោះបឋមដល់អាយុជីវិតមនុស្ស សត្វ ទ្រព្យ- | ➢ រៀបចំនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពធន់និងភាពបន្សាំទៅនឹងការប្រែប្រួល |

| លក្ខណសម្បត្តិ | សកម្មភាពជាអាទិភាព | សកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ |
|---|---|---|
| **និងជំងឺឆ្លងរាតត្បាត** | សម្បត្តិ ដើម្បីការពារនិងទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនានា<br>➢ ពង្រឹងសមត្ថភាពធន់និងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងហានិភ័យនៃគ្រោះមហន្តរាយ។ | អាកាសធាតុ ហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានា<br>➢ រៀបចំនិងអនុវត្តការបណ្តុះបណ្តាល ការអប់រំ និងការផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ ហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាត<br>➢ រៀបចំផែនការទុកជាមុន អំពីការសង្គ្រោះបឋមដល់អាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ ដើម្បីការពារនិងទប់ស្កាត់ហានិភ័យនៃគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងជំងឺឆ្លងរាតត្បាតនានា<br>➢ រៀបចំនិងអនុវត្តគម្រោងនិងសកម្មភាពពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពធន់និងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ហានិភ័យគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានា<br>➢ រៀបចំនិងអនុវត្តការអប់រំ ការផ្សព្វផ្សាយ និងការយល់ដឹងអំពីផែនការទុកជាមុន<br>➢ អនុវត្តដំណោះស្រាយនិងវិធានការនានា ដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដូចជាជំងឺCOVID-19និងជំងឺឆ្លងផ្សេងទៀត<br>➢ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រការគ្រប់គ្រង និងការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ។ |

## ៥-យន្តការអនុវត្តនិងតួនាទី ភារកិច្ច

សៀវភៅណែនាំនេះត្រូវអនុវត្តដោយក្រសួង ស្ថាប័ន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងឬស្ថាប័ននីមួយៗ រួមមានដូចខាងក្រោម៖

### ៥.១-ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃក្នុងតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាល ទទួលខុសត្រូវក្នុងការដឹកនាំនិងការសម្របសម្រួលជាមួយនឹងស្ថាប័នអនុវត្តទាំងអស់ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ

ក្នុងការអនុវត្តសៀវភៅណែនាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

**៥.២-លេខាធិការដ្ឋាន គ.ភ.ឃ.ស.**

លេខាធិការដ្ឋាន គ.ភ.ឃ.ស. ទទួលខុសត្រូវជួយក្រសួងមហាផ្ទៃក្នុងការគ្រប់គ្រង ការសម្របសម្រួល និងការអនុវត្តប្រចាំថ្ងៃនូវគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។ ការទទួលខុសត្រូវជាក់លាក់របស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. មានដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែង និងផែនការរយៈពេលមធ្យមស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- រៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន ស្តីពីការសហការសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងជាស់តឿនក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សហការរៀបចំលិខិតបទដ្ឋានគតិយុត្តនិងសេចក្តីណែនាំពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយដើម្បីដាក់ជូនក្រសួងមហាផ្ទៃពិនិត្យនិងអនុម័ត
- ណែនាំនិងគាំទ្រស្ថាប័នអនុវត្តនានា ក្នុងការរៀបចំនិងការអនុវត្តផែនការសកម្មភាពនិងថវិកាស្តីពីការអនុវត្តគោលនយោបាយ
- ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំនានាពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សម្របសម្រួល តាមដាន និងផ្តល់ការគាំទ្របច្ចេកទេសដល់ស្ថាប័ននានា ក្នុងការអនុវត្តគោលនយោបាយ
- ណែនាំនិងផ្តល់យោបល់លើការរៀបចំនិងការអនុវត្តកម្មវិធីប្រលងប្រណាំងប្រចាំឆ្នាំ ដែលរៀបចំដោយក្រសួង ស្ថាប័ននានា អំពីការអនុវត្តគោលនយោបាយ
- អនុវត្តការតាមដាននិងការវាយតម្លៃលើការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- កៀរគរការចូលរួមនិងការគាំទ្រពីដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- បូកសរុបនិងរៀបចំរបាយការណ៍នានាជូនក្រសួងមហាផ្ទៃ អំពីលទ្ធផលនៃការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

**៥.៣-ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**

- ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណតាមដំណាក់កាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»កម្មវិធីកំណែទម្រង់អភិបាលកិច្ច កម្មវិធីកំណែទម្រង់តាមវិស័យ ក៏ដូចជាសភាពការណ៍នានារបស់ប្រទេសជាតិ និងសភាពការណ៍រីកចម្រើនថ្មីៗនៅមូលដ្ឋាន
- លើកកម្ពស់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបំពេញការងារតាមរយៈការត្រួតពិនិត្យ ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោង កម្មវិធី និងផែនការនានានៅតាមមូលដ្ឋាន ស្របតាមជំនាញ តួនាទី និងភារកិច្ចរបស់ខ្លួន
- សហការជំរុញនិងលើកកម្ពស់គណនេយ្យភាពរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព

- សហការក្នុងការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន និងចុះជួបប្រាស្រ័យទាក់ទងផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ
- សម្របសម្រួលនិងសហការក្នុងការដោះស្រាយបញ្ហាប្រឈម និងការលំបាកនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- សហការជាមួយនឹងក្រសួង ស្ថាប័ន ក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការចុះតាមដាន ការចុះត្រួតពិនិត្យ និងការចុះរំលឹកដាស់តឿនរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- លើកកម្ពស់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សម្របសម្រួលនិងសហការជាមួយនឹងដៃគូអភិវឌ្ឍ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលឬអង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ដើម្បីកៀរគរធនធាននានាសម្រាប់អនុវត្តគោលនយោបាយ។

### ៨.៤-ក្រសួង ស្ថាប័ន

- រៀបចំក្រុមការងារដើម្បីជួយរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងជួយតាមដាន ត្រួតពិនិត្យនិងរំលឹកដាស់តឿនរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តលក្ខណសម្បត្តិនៃគោលនយោបាយដែលពាក់ព័ន្ធនឹងវិស័យជំនាញរបស់ខ្លួន
- រៀបចំនិងវិភាជថវិកាពីថវិការបស់ក្រសួង ស្ថាប័នសាមីសម្រាប់អនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន
- រៀបចំនិងបញ្ចូលសកម្មភាពពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន
- រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការចុះតាមដាន ការចុះត្រួតពិនិត្យ និងការចុះរំលឹកដាស់តឿនរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សម្របសម្រួលនិងសហការជាមួយនឹងដៃគូអភិវឌ្ឍ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលឬអង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ដើម្បីកៀរគរធនធាននានាសម្រាប់អនុវត្តគោលនយោបាយ គ.ភ.ឃ.ស.
- រៀបចំនិងអនុវត្តកម្មវិធីប្រលងប្រណាំងប្រចាំឆ្នាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ពាក់ព័ន្ធនឹងវិស័យរបស់ខ្លួន
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តគោលនយោបាយ ដើម្បីដាក់ជូនលេខាធិការដ្ឋាន គ.ភ.ឃ.ស.នៃក្រសួងមហាផ្ទៃ។

### ៨.៥-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រៅពីភារកិច្ចក្នុងនាមជាក្រសួង ស្ថាប័នដូចបានរៀបរាប់ខាងលើ ភារកិច្ចជាក់លាក់នានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន៖ ៧.៤

- រៀបចំសេចក្តីណែនាំស្តីពីការរៀបចំនិងការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- តាមដាន ត្រួតពិនិត្យ និងគាំទ្រក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការវិភាជថវិកានៃការរៀបចំគម្រោងថវិកានិងការអនុវត្តថវិកាសម្រាប់គាំទ្រគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"។

**៨.៦-រដ្ឋបាលរាជធានី ខេត្ត**

- រៀបចំនិងវិភាជថវិកាពីថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តសកម្មភាពនានានៃផែនការសកម្មភាពនិងថវិការបស់គណៈបញ្ជាការឯកភាព ដែលត្រូវទទួលខុសត្រូវអនុវត្តដោយរដ្ឋបាលរាជធានី ខេត្ត
- រៀបចំនិងដាក់បញ្ចូលគម្រោង សកម្មភាពនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំនិងបញ្ចូលសកម្មភាពពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន
- សហការនិងគាំទ្រគណៈបញ្ជាការឯកភាព ក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការចុះតាមដាន ការចុះត្រួតពិនិត្យ និងការចុះគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្របតាមតួនាទី ភារកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន
- សម្របសម្រួលនិងសហការជាមួយនឹងដៃគូអភិវឌ្ឍ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ដើម្បីកៀរគរធនធាននានាសម្រាប់អនុវត្តគោលនយោបាយ **គ.ភ.ឃ.ស.**។

**៨.៧-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត**

- រៀបចំលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត
- រៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការចុះតាមដាន ការចុះត្រួតពិនិត្យ និងការចុះគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សម្របសម្រួលនិងសហការជាមួយនឹងមន្ទីរឬអង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- រៀបចំកិច្ចប្រជុំឬសិក្ខាសាលាបូកសរុបរយៈពេលយ៉ាងយូរ៦ខែម្តង ដើម្បីវាយតម្លៃការងារ ដកស្រង់បទពិសោធ និងលើកទិសដៅសម្រាប់អនុវត្តបន្ត
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការអនុវត្តគោលនយោបាយជូនលេខាធិការដ្ឋាន **គ.ភ.ឃ.ស.**នៃក្រសួងមហាផ្ទៃ។ របាយការណ៍នេះត្រូវបូកសរុបរបាយការណ៍របស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់។

៩.៨-ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

- សហការរៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- រៀបចំនិងអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន
- ចាត់វិធានការជាក់ស្តែងនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សម្របសម្រួលនិងគាំទ្រការអនុវត្តកម្មវិធីប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- តាមដាន ត្រួតពិនិត្យ និងគាំទ្រអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

៩.៩-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត

- សហការរៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- ចាត់វិធានការជាក់ស្តែងនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សហការនិងផ្តល់ការគាំទ្រសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

៩.១០-រដ្ឋបាលក្រុង ស្រុក ខណ្ឌ

- រៀបចំនិងវិភាជថវិកាពីថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តសកម្មភាពនានានៃផែនការសកម្មភាពនិងថវិការបស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលត្រូវទទួលខុសត្រូវអនុវត្តដោយរដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- រៀបចំនិងដាក់បញ្ចូលគម្រោង សកម្មភាពនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំនិងបញ្ចូលសកម្មភាពពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន
- សហការនិងគាំទ្រគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការចុះតាមដាន ការចុះត្រួតពិនិត្យ និងការចុះគាំទ្រដល់ឃុំ សង្កាត់ ក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន
- សម្របសម្រួលនិងសហការជាមួយនឹងដៃគូអភិវឌ្ឍ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ដើម្បីកៀរគរធនធានសម្រាប់អនុវត្ត គ.ភ.ឃ.ស.។

### ៩.១១-គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- រៀបចំលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្តីពីការចុះតាមដាន ការចុះត្រួតពិនិត្យ និងការចុះគាំទ្រដល់ឃុំ សង្កាត់ ក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- រៀបចំកិច្ចប្រជុំឬសិក្ខាសាលាបូកសរុបរយៈពេលយ៉ាងយូរ៦ខែម្តង ដើម្បីវាយតម្លៃការងារ ដកស្រង់បទពិសោធ និងលើកទិសដៅបន្ត
- រៀបចំនិងផ្ញើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការអនុវត្តគោលនយោបាយ ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីបូកសរុបនិងផ្ញើជូនលេខាធិការដ្ឋាន **គ.ភ.យ.ស.**នៃក្រសួងមហាផ្ទៃ។ របាយការណ៍នេះត្រូវបូកសរុបបញ្ចូលរបាយការណ៍របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។

### ៩.១២-អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ

- សហការរៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- រៀបចំនិងអនុវត្តសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ចាត់វិធានការជាក់ស្តែងនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សម្របសម្រួលនិងគាំទ្រការអនុវត្តកម្មវិធីប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សហការនិងគាំទ្រប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

### ៩.១៣-មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ

- សហការរៀបចំនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- ចាត់វិធានការជាក់ស្តែងនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សហការនិងផ្តល់ការគាំទ្រសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

### ៩.១៤-រដ្ឋបាលឃុំ សង្កាត់

- រៀបចំក្រុមការងារឬគណៈកម្មការដែលមានស្រាប់ ដើម្បីជួយរដ្ឋបាលឃុំ សង្កាត់ ក្នុងការត្រួតពិនិត្យលើការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

- រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្ដីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- ចាត់វិធានការដាក់ស្តែងនានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សហការ ចូលរួម និងអនុវត្តកម្មវិធីប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលរៀបចំដោយក្រសួង ស្ថាប័ននានា
- ពង្រឹងនិងលើកទឹកចិត្តប៉ុស្តិ៍នគរបាលរដ្ឋបាល ថ្នាក់ដឹកនាំភូមិ កម្លាំងប្រជាការពារ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និងអង្គការសហគមន៍មូលដ្ឋាននានា ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- រៀបចំកិច្ចប្រជុំឬសិក្ខាសាលាបូកសរុបរយៈពេលយ៉ាងយូរ៦ខែម្តង ដើម្បីវាយតម្លៃការងារ ដកស្រង់បទពិសោធ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្ត
- រៀបចំវិភាជនិងបញ្ចូលថវិកាសម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់
- រៀបចំនិងដាក់បញ្ចូលការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួលនិងសហការជាមួយនឹងដៃគូអភិវឌ្ឍ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលឬអង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ដើម្បីកៀរគរធនធានសម្រាប់អនុវត្ត គ.ភ.ឃ.ស.
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការអនុវត្តគោលនយោបាយជូនគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបូកសរុបនិងធ្វើជូនគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត។

៥.១៥-ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់

- ចាត់ចែងនិងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំស្ដីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រួមបញ្ចូលទាំងការអនុវត្តតួនាទីនិងភារកិច្ចតាមទម្រង់ការងារនគរបាលនិងសហគមន៍ ការពង្រឹងកម្លាំងប្រជាការពារនៅតាមភូមិ ឃុំ សង្កាត់ និងសហការជាមួយនឹងកម្លាំងសមត្ថកិច្ចនានា។ល។
- សហការ ចូលរួម និងអនុវត្តកម្មវិធីប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលរៀបចំដោយក្រសួង ស្ថាប័ននានា
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការអនុវត្តគោលនយោបាយជូនរដ្ឋបាលឃុំ សង្កាត់។

## ៦-ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.)

ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការសកម្មភាពនិងថវិកាស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។ ដំណើរការនៃការរៀបចំផែនការសកម្មភាពនិងថវិកាស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-

សង្កាត់មានសុវត្ថិភាព» ត្រូវអនុវត្តផ្អែកតាមដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំនិងដាក់ឱ្យអនុវត្តដោយប្រកាសអន្តរក្រសួងរវាងក្រសួងផែនការ និងក្រសួងមហាផ្ទៃ និងដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំនិងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

លេខាធិការដ្ឋាន **គ.ភ.ឃ.ស.** ត្រូវសហការជិតស្និទ្ធជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានត្រួតពិនិត្យ និងគាំទ្រក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនិងការអនុវត្តផែនការសកម្មភាពនិងថវិកាស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»របស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

### ៦.១-ក្រសួង ស្ថាប័ន

ក្រុមការងារទទួលបន្ទុកការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»របស់ក្រសួង ស្ថាប័ននីមួយៗ ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាស្តីពីការតាមដាន ការត្រួតពិនិត្យ និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រួមបញ្ចូលទាំងសកម្មភាពនិងថវិកានានាសម្រាប់រៀបចំនិងអនុវត្តកម្មវិធីប្រលងប្រណាំងអំពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»និងសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

ការរៀបចំ **ផ.ស.ថ.**ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវយកចិត្តទុកដាក់លើឯកសារនិងកិច្ចការសំខាន់ៗ ដូចខាងក្រោម៖

- លក្ខណសម្បត្តិទាំង៧នៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ដែលពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ
- សកម្មភាពជាអាទិភាព និងវិធានការដាក់ស្តែងពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ។

ផែនការសកម្មភាពនិងថវិកាទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមី ដើម្បីធានាថាក្រសួង ស្ថាប័នមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

### ៦.២-ថ្នាក់រាជធានី ខេត្ត

នៅថ្នាក់រាជធានី ខេត្ត លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តទទួលខុសត្រូវក្នុងការរៀបចំ **ផ.ស.ថ.**ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»របស់រដ្ឋបាលរាជធានី ខេត្ត។

ផែនការសកម្មភាពនិងថវិកាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត និងភាគីពាក់ព័ន្ធនានា ដើម្បីធានាថាស្ថាប័នពាក់ព័ន្ធទាំងអស់មានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

### ៦.៣-ថ្នាក់ក្រុង ស្រុក ខណ្ឌ

នៅថ្នាក់ក្រុង ស្រុក ខណ្ឌ លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ទទួលខុសត្រូវក្នុងការរៀបចំ **ផ.ស.ថ.** ស្ដីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ផែនការសកម្មភាពនិងថវិកាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ និងភាគីពាក់ព័ន្ធនានា ដើម្បីធានាថាស្ថាប័នពាក់ព័ន្ធទាំងអស់មានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

### ៦.៤-ថ្នាក់ឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំសកម្មភាពនិងវិភាជថវិការបស់ខ្លួនសម្រាប់រៀបចំនិងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រួមបញ្ចូលទាំងសកម្មភាពពាក់ព័ន្ធនឹងការចាត់វិធានការដាក់ស្ដែងនានា។

ផែនការសកម្មភាពនិងថវិកាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនិងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាថារដ្ឋបាលឃុំ សង្កាត់មានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

## ៧-ការអនុវត្តផែនការ

### ៧.១-យន្តការអនុវត្ត

ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ស្ថិតក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃដែលជាសេនាធិការជូនរាជរដ្ឋាភិបាល។ លេខាធិការដ្ឋាន **គ.ភ.ឃ.ស.** ទទួលខុសត្រូវជួយក្រសួងមហាផ្ទៃ ក្នុងការគ្រប់គ្រងនិងការសម្របសម្រួលកិច្ចការប្រចាំថ្ងៃនៃការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយសហការជិតស្និទ្ធជាមួយនឹងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធ។

នៅតាមក្រសួង ស្ថាប័ន ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ស្ថិតក្រោមការដឹកនាំរបស់ប្រធានស្ថាប័ន ដោយមានក្រុមការងារជាជំនួយការក្នុងការគ្រប់គ្រងនិងការសម្របសម្រួលលើកិច្ចការប្រចាំថ្ងៃនៃការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្រោមការដឹកនាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានលេខាធិការដ្ឋានជាជំនួយការក្នុងការគ្រប់គ្រងនិងការសម្របសម្រួលលើកិច្ចការប្រចាំថ្ងៃនៃការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

នៅថ្នាក់ឃុំ សង្កាត់ ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ស្ថិតក្រោមការដឹកនាំរបស់មេឃុំ ចៅសង្កាត់ ដោយមានប៉ុស្តិ៍នគរបាលរដ្ឋបាល គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងភាគីពាក់ព័ន្ធផ្សេងទៀត ចាត់ចែងនិងអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ៧.២-ដំណើរការអនុវត្ត

ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ធ្វើឡើងតាមរយៈផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំដែលត្រូវរៀបចំដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតួនាទី ភារកិច្ច និង

ការទទួលខុសត្រូវរបស់ខ្លួន។

អាស្រ័យហេតុនេះ ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយផ្អែកលើឯកសារសំខាន់ដូចខាងក្រោម៖

- កម្មវិធីវិនិយោគបីឆ្នាំរំកិល
- ផែនការយុទ្ធសាស្ត្រថវិកាដែលបានអនុម័ត
- គម្រោងថវិកាប្រចាំឆ្នាំដែលបានអនុម័ត
- លក្ខណសម្បត្តិទាំង៧នៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ដែលពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តនីមួយៗ
- សកម្មភាពជាអាទិភាព និងវិធានការដាក់ស្តែងពាក់ព័ន្ធនឹងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ។

ជាទូទៅ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំ **ផ.ស.ថ.**ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» តាមទម្រង់ចំនួន២ រួមមាន៖

**ទម្រង់ទី១ស្តីពីក្របខណ្ឌលទ្ធផលនៃផ.ស.ថ.៖** សង្ខេបអំពីគោលដៅនិងលទ្ធផលរំពឹងទុកនានា(លក្ខណសម្បត្តិទាំង៧) រួមបញ្ចូលទាំងសូចនាករ និងចំណុចដៅដែលត្រូវសម្រេច។

**ទម្រង់ទី២ស្តីពីសកម្មភាពនិងថវិកាលម្អិតនៃផ.ស.ថ.៖** រៀបរាប់អំពីសកម្មភាពនានាដែលត្រូវអនុវត្តតាមលក្ខណសម្បត្តិនីមួយៗ ថវិកា ក្របខណ្ឌពេលវេលា និងអង្គភាពទទួលខុសត្រូវ។

**ទម្រង់ទី១-ក្របខណ្ឌលទ្ធផល**

| លទ្ធផល | សូចនាករ | ទិន្នន័យដើមគ្រា | ចំណុចដៅ | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| គោលដៅ៖ | | | | |
| លក្ខណសម្បត្តិទី១៖ | | | | |
| លក្ខណសម្បត្តិទី២៖ | | | | |
| លក្ខណសម្បត្តិទី៣៖ | | | | |
| លក្ខណសម្បត្តិទី៤៖ | | | | |
| លក្ខណសម្បត្តិទី៥៖ | | | | |
| លក្ខណសម្បត្តិទី៦៖ | | | | |
| លក្ខណសម្បត្តិទី៧៖ | | | | |

ជារួម គោលដៅរបស់ផ.ស.ថ. របស់ស្ថាប័នអនុវត្តនីមួយៗ ស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» គឺ*រួមចំណែកក្នុងការកសាងនិងការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីគ្រោះមហន្តរាយនិងជំងឺឆ្លងរាតត្បាត នៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ។* ៧.+

ដើម្បីសម្រេចបាននូវគោលដៅខាងលើ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តលទ្ធផលរំពឹងទុកដែលជាលក្ខណសម្បត្តិនៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ទាំង៧។ ដូច្នេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យមើលនិងជ្រើសរើសយកលក្ខណសម្បត្តិណាដែលស្របជាមួយនឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក្នុងចំណោមលក្ខណសម្បត្តិទាំង៧មកអនុវត្តដើម្បីជានាការសម្រេចបាននូវគោលដៅ។ បន្ទាប់មក ក្រសួង ស្ថាប័ន និងរដ្ឋបាលទាំងនេះត្រូវកំណត់សូចនាករ ទិន្នន័យដើមគ្រា ចំណុចដៅ និងមធ្យោបាយផ្ទៀងផ្ទាត់សម្រាប់គោលដៅនិងលក្ខណសម្បត្តិនីមួយៗ។

**ទម្រង់ទី២-តារាងសកម្មភាពនិងថវិកាលម្អិតនៃ ផ.ស.ថ.**

| លទ្ធផលនិងសកម្មភាព | ថវិកា | ទីតាំង | ក្របខណ្ឌពេលវេលា | | | | | | | | | | | | អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | |
| លក្ខណសម្បត្តិទី១៖ | | | | | | | | | | | | | | | |
| សកម្មភាព ១.១៖......... | | | | | | | | | | | | | | | |
| សកម្មភាព ១.២៖ ......... | | | | | | | | | | | | | | | |
| លក្ខណសម្បត្តិទី២៖ | | | | | | | | | | | | | | | |
| សកម្មភាព ២.១៖......... | | | | | | | | | | | | | | | |
| សកម្មភាព ២.២៖ ......... | | | | | | | | | | | | | | | |
| លក្ខណសម្បត្តិទី៣៖ | | | | | | | | | | | | | | | |
| សកម្មភាព ៣.១៖......... | | | | | | | | | | | | | | | |
| សកម្មភាព ៣.២៖ ......... | | | | | | | | | | | | | | | |
| លក្ខណសម្បត្តិទី៤៖ | | | | | | | | | | | | | | | |
| សកម្មភាព ៤.១៖......... | | | | | | | | | | | | | | | |
| សកម្មភាព ៤.២៖ ......... | | | | | | | | | | | | | | | |
| លក្ខណសម្បត្តិទី៥៖ | | | | | | | | | | | | | | | |
| សកម្មភាព ៥.១៖......... | | | | | | | | | | | | | | | |
| សកម្មភាព ៥.២៖ ......... | | | | | | | | | | | | | | | |
| លក្ខណសម្បត្តិទី៦៖ | | | | | | | | | | | | | | | |
| សកម្មភាព ៦.១៖......... | | | | | | | | | | | | | | | |
| សកម្មភាព ៦.២៖ ......... | | | | | | | | | | | | | | | |
| លក្ខណសម្បត្តិទី៧៖ | | | | | | | | | | | | | | | |
| សកម្មភាព ៧.១៖......... | | | | | | | | | | | | | | | |
| សកម្មភាព ៧.២៖ ......... | | | | | | | | | | | | | | | |
| ថវិកាសរុប | | | | | | | | | | | | | | | |

ផ្អែកលើលក្ខណសម្បត្តិដែលត្រូវសម្រេចក្នុងទម្រង់ទី១ និងសកម្មភាពលម្អិតសម្រាប់អនុវត្តគោលនយោបាយក្នុងឆ្នាំនីមួយៗដូចបានកំណត់ក្នុងផ្នែកទី៤ខាងលើ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់សកម្មភាពនានាដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់ខ្លួន ដើម្បីសម្រេចបាននូវលក្ខណសម្បត្តិ

នីមួយៗ។ សកម្មភាពនីមួយៗត្រូវកំណត់ឱ្យបានច្បាស់លាស់ អំពីថវិកា ទីតាំងអនុវត្ត ក្របខណ្ឌពេលវេលា និងអង្គភាពទទួលខុសត្រូវ(ទម្រង់ទី២)។

ចំពោះក្រសួង ស្ថាប័ន និងរាជធានី ខេត្តត្រូវផ្ញើឯកសារថតចម្លង១ច្បាប់នៃ **ផ.ស.ថ.**(ទម្រង់ទី១និងទម្រង់ទី២) ជូនលេខាធិការដ្ឋាន**គ.ភ.ឃ.ស.** ដើម្បីជាមូលដ្ឋានក្នុងការតាមដាននិងការពិនិត្យមើលធៀបនឹងរបាយការណ៍ដែលក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ផ្ញើទៅលេខាធិការដ្ឋាន។

ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវផ្ញើឯកសារថតចម្លង១ច្បាប់នៃ **ផ.ស.ថ.** ជូនរដ្ឋបាលរាជធានី ខេត្ត ដើម្បីជាមូលដ្ឋានក្នុងការតាមដាននិងការពិនិត្យមើលវឌ្ឍនភាពធៀបនឹងរបាយការណ៍ដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ផ្ញើឱ្យរដ្ឋបាលរាជធានី ខេត្ត។

## ៨-ការត្រួតពិនិត្យនិងការវាយតម្លៃ

ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»ត្រូវធ្វើការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ដើម្បីធានាថាគោលនយោបាយនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

សកម្មភាពនិងថវិកានានាសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃ ត្រូវដាក់បញ្ចូលក្នុង**ផ.ស.ថ.**ស្ដីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»របស់ស្ថាប័នអនុវត្តនីមួយៗ។

### ៨.១-ការត្រួតពិនិត្យ

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តការតាមដាននិងការត្រួតពិនិត្យជាប្រចាំលើការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដើម្បីពិនិត្យមើលពីវឌ្ឍនភាពនិងបញ្ហាប្រឈមនៃការអនុវត្តគោលនយោបាយធៀបនឹងសកម្មភាពនិងថវិកាលម្អិតដែលបានកំណត់នៅក្នុង**ផ.ស.ថ.**។ ទន្ទឹមនឹងនេះក្នុងកំលុងពេលនៃការអនុវត្ត**ផ.ស.ថ.** ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំកិច្ចប្រជុំឬសិក្ខាសាលាបូកសរុបរយៈពេលយ៉ាងយូរ៦ខែម្ដង ដើម្បីវាយតម្លៃការងារ ដកស្រង់បទពិសោធ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្ត។

ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័ន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងភាគីពាក់ព័ន្ធ ត្រូវចុះមូលដ្ឋានជាប្រចាំ ដើម្បីតាមដាន ត្រួតពិនិត្យ ដាស់តឿន និងផ្ដល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ក្នុងការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

### ៨.២-ការវាយតម្លៃ

នៅដំណាច់ឆ្នាំនីមួយៗ ស្ថាប័នអនុវត្តទាំងអស់ត្រូវរៀបចំកិច្ចប្រជុំឬសិក្ខាសាលាឆ្លុះបញ្ចាំងស្ដីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដើម្បីពិនិត្យមើលអំពីសមិទ្ធផលសម្រេចបាន បញ្ហាប្រឈមដែលជួបប្រទះ ដកស្រង់បទពិសោធ និងលើកទិសដៅសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។ ការវាយតម្លៃនេះត្រូវផ្ដោតជាសំខាន់លើសមិទ្ធផលដែលសម្រេចបានធៀបនឹងលទ្ធផលរំពឹងទុក(លក្ខណសម្បត្តិរបស់«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព») និងសូចនាករនានាដែលបានកំណត់នៅក្នុងក្របខណ្ឌលទ្ធផល(ទម្រង់ទី១នៃ ផ.ស.ថ.)។ អាស្រ័យហេតុនេះ ក្នុងកិច្ចប្រជុំឬសិក្ខាសាលាវាយតម្លៃត្រូវបង្ហាញអំពីសមិទ្ធផលសំខាន់ៗដែលសម្រេចបាន

ធៀបនឹងក្របខណ្ឌលទ្ធផល និងបញ្ហាប្រឈមជួបប្រទះសម្រាប់ជាមូលដ្ឋានក្នុងការពិភាក្សា។

៨.៣-ការរៀបចំរបាយការណ៍

ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដើម្បីផ្ញើជូនលេខាធិការដ្ឋាន **គ.ភ.ឃ.ស.** នៃក្រសួងមហាផ្ទៃ។ របាយការណ៍រាជធានី ខេត្តត្រូវបូកបញ្ចូលរបាយការណ៍ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាសស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ហើយផ្ញើរបាយការណ៍នេះជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំរបាយការណ៍របស់ខ្លួនដោយបូកបញ្ចូលរបាយការណ៍ឃុំ សង្កាត់ ដើម្បីជូនរដ្ឋបាលរាជធានី ខេត្ត។

ស្ថាប័នអនុវត្តទាំងអស់ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពតាមទម្រង់ដូចខាងក្រោម៖

**ទម្រង់ទី៣-របាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស**

១-សេចក្តីសង្ខេបអំពីវឌ្ឍនភាពសំខាន់ៗ

២-បញ្ហាប្រឈមជួបប្រទះ

៣-វឌ្ឍនភាពលម្អិតតាមសកម្មភាពនីមួយៗ

| លទ្ធផលនិងសកម្មភាព | ស្ថានភាពអនុវត្ត | វឌ្ឍនភាព | សម្គាល់ |
|---|---|---|---|
| លក្ខណសម្បត្តិទី១៖ | | | |
| សកម្មភាព ១.១៖ ......... | | | |
| សកម្មភាព ១.២៖ ......... | | | |
| លក្ខណសម្បត្តិទី២៖ | | | |
| សកម្មភាព ២.១៖......... | | | |
| សកម្មភាព ២.២៖ ......... | | | |
| លក្ខណសម្បត្តិទី៣៖ | | | |
| សកម្មភាព ៣.១៖......... | | | |
| សកម្មភាព ៣.២៖ ......... | | | |
| លក្ខណសម្បត្តិទី៤៖ | | | |
| សកម្មភាព ៤.១៖......... | | | |
| សកម្មភាព ៤.២៖ ......... | | | |
| លក្ខណសម្បត្តិទី៥៖ | | | |
| សកម្មភាព ៥.១៖......... | | | |
| សកម្មភាព ៥.២៖ ......... | | | |
| លក្ខណសម្បត្តិទី៦៖ | | | |
| សកម្មភាព ៦.១៖......... | | | |
| សកម្មភាព ៦.២៖ ......... | | | |

| លទ្ធផលនិងសកម្មភាព | ស្ថានភាពអនុវត្ត | វឌ្ឍនភាព | សម្គាល់ |
|---|---|---|---|
| លក្ខណសម្បត្តិទី៧៖ | | | |
| សកម្មភាព ៧.១៖......... | | | |
| សកម្មភាព ៧.២៖ ......... | | | |

## ទម្រង់ទី៤-របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ

### ១-សេចក្តីសង្ខេបអំពីវឌ្ឍនភាពសំខាន់ៗ

### ២-បញ្ហាប្រឈមជួបប្រទះ

### ៣-វឌ្ឍនភាពលម្អិតតាមសកម្មភាពនីមួយៗ

| លទ្ធផល | សូចនាករ | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាព |
|---|---|---|---|---|
| លក្ខណសម្បត្តិទី១៖ | | | | |
| លក្ខណសម្បត្តិទី២៖ | | | | |
| លក្ខណសម្បត្តិទី៣៖ | | | | |
| លក្ខណសម្បត្តិទី៤៖ | | | | |
| លក្ខណសម្បត្តិទី៥៖ | | | | |
| លក្ខណសម្បត្តិទី៦៖ | | | | |
| លក្ខណសម្បត្តិទី៧៖ | | | | |

### ៨.៤-ការប្រលងប្រណាំង

#### ក-រៀបចំការប្រលងប្រណាំង

ការប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានរៀបចំឡើងក្នុងគោលបំណងជំរុញលើកទឹកចិត្តរដ្ឋបាលឃុំ សង្កាត់ ឱ្យខិតខំយកចិត្តទុកដាក់និងប្រឹងប្រែងអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាព សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ អនាម័យ បរិស្ថាន និងសុខុមាលភាព ជូនប្រជាពលរដ្ឋ។ អាស្រ័យហេតុនេះ ចលនាប្រលងប្រណាំងអំពីការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវអនុវត្តជាប្រចាំដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចនានាស្របតាមតួនាទី និងភារកិច្ចរបស់ខ្លួន។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវរៀបចំកម្មវិធីប្រលងប្រណាំងឱ្យបានច្បាស់លាស់និងមានលក្ខណៈសាមញ្ញ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលឃុំ សង្កាត់ងាយយល់និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។ ធាតុសំខាន់ៗនៃកម្មវិធីប្រលងប្រណាំងរួមមានកិច្ចដំណើរការនិងនីតិវិធី យន្តការអនុវត្ត សូចនាករ លក្ខណវិនិច្ឆ័យ និងរូបមន្តជាដើម។ ជាមួយគ្នានេះដែរ កម្មវិធីប្រលងប្រណាំងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិនិងភាគីពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ការចូលរួម តម្លាភាព និងប្រសិទ្ធភាពនៃកម្មវិធីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំឯកសារស្តីពីកម្មវិធីប្រលងប្រណាំងស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»នៅថ្នាក់ឃុំ សង្កាត់ ក្នុងវិស័យរបស់ខ្លួន ហើយផ្ញើជូនលេខាធិការដ្ឋាន គ.ភ.យ.ស.

ពិនិត្យនិងផ្តល់យោបល់ដើម្បីធានាថាកម្មវិធីប្រលងប្រណាំងនេះត្រូវបានរៀបចំនិងអនុវត្តស្របតាមគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ និងសេចក្តីណែនាំនានា។

ជារួម កម្មវិធីប្រលងប្រណាំងត្រូវរៀបចំដោយបញ្ចូលនូវធាតុសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណងនិងគោលដៅ
- វិសាលភាព
- សូចនាករសម្រាប់ប្រលងប្រណាំង
- ដំណើរការនិងនីតិវិធីសម្រាប់អនុវត្តការប្រលងប្រណាំងរួមបញ្ចូលទាំងការដាក់ពិន្ទុ រូបមន្តនិងវិធីសាស្ត្រសម្រាប់គណនាពិន្ទុ ព្រមទាំងការផ្តល់ពានរង្វាន់លើកទឹកចិត្តជាដើម
- ការផ្សព្វផ្សាយនិងការបណ្តុះបណ្តាលអំពីការប្រលងប្រណាំង
- ការត្រួតពិនិត្យនិងការគាំទ្រលើការអនុវត្តនៃការប្រលងប្រណាំង។

**ខ-គោលការណ៍ប្រលងប្រណាំង**

ក្នុងការរៀបចំនិងការអនុវត្តលើការប្រលងប្រណាំង ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវគោរពតាមគោលការណ៍សំខាន់ៗមួយចំនួន ដូចខាងក្រោម៖

**១-សាមញ្ញ៖** ដំណើរការនិងនីតិវិធីសម្រាប់អនុវត្តការប្រលងប្រណាំង ត្រូវរៀបចំឱ្យមានលក្ខណៈសាមញ្ញ ខ្លី និងងាយយល់សម្រាប់ឃុំ សង្កាត់ និងភាគីពាក់ព័ន្ធទាំងអស់។ ជាមួយគ្នានេះដែរ ការរៀបចំប្រលងប្រណាំងត្រូវធានាថានឹងមិនបន្ថែមបន្ទុកការងារធ្ងន់ធ្ងរដល់រដ្ឋបាលឃុំ សង្កាត់ឡើយ

**២-ច្បាស់លាស់៖** ការប្រលងប្រណាំងត្រូវរៀបចំដោយផ្តោតលើប្រធានបទសំខាន់ៗជាក់លាក់ក្នុងវិស័យនីមួយៗ ដោយមានការកំណត់សូចនាករ ពិន្ទុ និងរូបមន្តសម្រាប់គណនាពិន្ទុច្បាស់លាស់និងត្រឹមត្រូវ ស្របតាមទ្រឹស្តីនៃគណិតវិទ្យានិងស្ថិតិ

**៣-យុត្តិធម៌៖** ការប្រលងប្រណាំងត្រូវអនុវត្តដោយគ្មានលម្អៀងចំពោះអ្នកចូលរួមប្រលងប្រណាំងទាំងអស់ ដូចជាការដាក់ពិន្ទុ ការគណនាពិន្ទុ និងការផ្សព្វផ្សាយព័ត៌មានអំពីការប្រលងប្រណាំងជាដើម

**៤-សមភាព៖** រដ្ឋបាលឃុំ សង្កាត់ទាំងអស់មានសិទ្ធិស្មើគ្នា ត្រូវបានផ្តល់ឱកាសនិងលក្ខខណ្ឌដូចគ្នាក្នុងការចូលរួមការប្រលងប្រណាំង

**៥-មានតម្លាភាព៖** ដំណើរការនិងនីតិវិធីសម្រាប់អនុវត្តការប្រលងប្រណាំង រួមបញ្ចូលទាំងសូចនាករ ការដាក់ពិន្ទុ និងរូបមន្តសម្រាប់គណនាពិន្ទុ ត្រូវធ្វើការផ្សព្វផ្សាយនិងការបណ្តុះបណ្តាលឱ្យបានទូលំទូលាយច្បាស់លាស់និងទាន់ពេលវេលា ដល់អ្នកចូលរួមប្រលងប្រណាំងនិងភាគីពាក់ព័ន្ធទាំងអស់។

**គ-យន្តការដឹកនាំការប្រលងប្រណាំង**

ការអនុវត្តចលនាប្រលងប្រណាំងគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវធ្វើឡើងស្របតាមលិខិតជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ១០៧ សជណ.មយ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ដែលបានណែនាំដូចខាងក្រោម៖

ក្រសួង ស្ថាប័ននានាដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាល ដែលជាលក្ខណសម្បត្តិទី**១**នៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវរៀបចំនិងដាក់ឱ្យអនុវត្ត នូវចលនាប្រលងប្រណាំងលើការផ្តល់សេវាសាធារណៈដែលស្ថិតក្រោមសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ។

ក្រសួងមហាផ្ទៃទទួលខុសត្រូវបន្តដឹកនាំចលនាប្រលងប្រណាំងពាក់ព័ន្ធនឹងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៅមូលដ្ឋានដែលជាលក្ខណសម្បត្តិទី**២** ទី**៣** និងទី**៤**នៃ គោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ ដែលជាលក្ខណសម្បត្តិទី**១**នៃគោលនយោបាយនេះ ដោយសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ក្រសួងយុត្តិធម៌ទទួលខុសត្រូវដឹកនាំចលនាប្រលងប្រណាំងពាក់ព័ន្ធនឹងការដោះស្រាយវិវាទនៅ មូលដ្ឋានក្រៅប្រព័ន្ធតុលាការដែលជាលក្ខណសម្បត្តិទី**៥**នៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

ក្រសួងបរិស្ថានទទួលខុសត្រូវដឹកនាំចលនាប្រលងប្រណាំងពាក់ព័ន្ធនឹងអនាម័យ សោភណភាព និង បរិស្ថានដែលជាលក្ខណសម្បត្តិទី**៦**នៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ។

ក្រសួងសុខាភិបាល និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទទួលខុសត្រូវដឹកនាំចលនា ប្រលងប្រណាំងពាក់ព័ន្ធនឹងការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាច សាហាវនានាដែលជាលក្ខណសម្បត្តិទី**៧**នៃគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

ក្រសួង ស្ថាប័នទាំងអស់ទទួលខុសត្រូវរៀបចំរបាយការណ៍ស្តីពីការប្រលងប្រណាំងក្នុងវិស័យរបស់ខ្លួន ជូនលេខាធិការដ្ឋាន **គ.ភ.ឃ.ស.** ដើម្បីបូកសរុបនិងរាយការណ៍ជូនរាជរដ្ឋាភិបាល៕ N.K

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១ គនស

# គោលនយោបាយ
# «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើងមានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានា នៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីជានាឱ្យជនគ្រប់រូប និងសង្គមទាំងមូល មានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។

ឆ្លងកាត់បទពិសោធន៍អស់រយៈពេល១០ឆ្នាំ ក្រសួងមហាផ្ទៃដោយមានការគាំទ្រ និងចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋាន និងអ្នកពាក់ព័ន្ធ បានចាត់តាំងអនុវត្តប្រកបដោយជោគជ័យ និងបានធ្វើការកែលម្អផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ជាបន្តបន្ទាប់ ឱ្យស្របតាមបរិបទនៃការអភិវឌ្ឍរីកចម្រើនរបស់សង្គមជាតិ។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឱ្យមានការចូលរួមគាំទ្រកាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរ ដូចខាងក្រោម៖

១. បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

២. កសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

I. លក្ខណសម្បត្តិរបស់ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។

២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។

៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។

៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ។

៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងរាល់ជំងឺឆ្លងពាក់ព័ន្ធរាងកាយសាហាវប្រកបដោយប្រសិទ្ធភាព ។

II. វិធានការជាមូលដ្ឋាន

លក្ខណសម្បត្តិទាំង០៧យ៉ាង នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានចាត់តាំងអនុវត្តតាមវិធានការជាមូលដ្ឋានដូចខាងក្រោម៖

១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត៖

ចាត់វិធានការឱ្យបានហ្មត់ចត់ និងទាន់ពេលវេលាក្នុងការលើកកម្ពស់ការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននានានៅគ្រប់វិស័យ នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ទាំងផ្នែកបរិមាណ គុណភាព ប្រសិទ្ធភាព តម្លាភាព ពោលគឺជំរុញឱ្យការផ្តល់សេវា និងកិច្ចអន្តរគមន៍នានាកាន់តែកៀកកិតនឹងប្រជាពលរដ្ឋ សំដៅបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋកាន់តែច្រើនឡើង។

២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ៖

-ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំអំពីច្បាប់ពាក់ព័ន្ធ និងផលប៉ះពាល់នានាដែលបណ្តាលមកពីបទល្មើសគ្រប់ប្រភេទ ជាពិសេសអំពើ លួច ឆក់ ប្លន់ ចាប់ជំរិតយកប្រាក់ ការប្រើប្រាស់អាវុធខុសច្បាប់ និងល្បែង

ស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសធនធានធម្មជាតិ និងបរិស្ថាន ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់។

- ត្រូវចាត់វិធានការក្នុងការបង្ការ ទប់ស្កាត់ឱ្យបានជាអតិបរមានូវការចរាចរ ការចែកចាយ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ព្រមទាំងខិតខំលុបបំបាត់ការដាំដុះ ការរក្សាទុក ការលួចកែច្នៃសារធាតុញៀនគ្រប់ប្រភេទតាមគ្រប់រូបភាពនៅតាមភូមិ ឃុំ សង្កាត់។

- ត្រូវជំរុញបំផុសចលនាអប់រំមហាជនដើម្បីចូលរួមបង្ការ ទប់ស្កាត់បទល្មើសគ្រឿងញៀនគ្រប់ប្រភេទ ជាពិសេសអនុវត្តឱ្យបានទូលំទូលាយនូវខ្លឹមសារទិសស្លោក «បីកុំ-មួយរាយការណ៍» ៖

❖ **បីកុំ ៖**

- **កុំរោភរ័ន្ធ** ៖ កុំជួញដូរ កុំចែកចាយ កុំធ្វើខ្នងបង្អែក កុំឃុបឃិតនិងកុំប្រើប្រាស់គ្រឿងញៀន។
- **កុំអន្តរាគមន៍** ៖ កុំរាំងការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ទោះបីជាក្រុមគ្រួសារ សាច់ញាតិ ឬមិត្តភ័ក្រក៏ដោយ។
- **កុំលើកលែង** ៖ កុំបន្ធូរបន្ថយការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ។ សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ និងស្មោះត្រង់វិជ្ជាជីវៈរបស់ខ្លួន ហើយជនគ្រប់រូបត្រូវគោរព និងអនុវត្តច្បាប់។

❖ **មួយរាយការណ៍៖** ត្រូវរាយការណ៍ ផ្តល់ព័ត៌មានដល់សមត្ថកិច្ចអំពីមុខសញ្ញាជួញដូរ ចែកចាយ ប្រើប្រាស់ ទីតាំងកែច្នៃ ផលិត និងទីតាំងស្តុកទុកគ្រឿងញៀន។

- ត្រូវសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ អនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន យុទ្ធសាស្ត្រទាំង០៥ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន បទបញ្ជាសារាចរណែនាំ និងផែនការយុទ្ធនាការក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាលតាមគ្រប់ដំណាក់កាល។

- ត្រូវជំរុញឱ្យមានការបំផុសចលនាចូលរួមសហការ គាំទ្រពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

### ៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍

- ជំរុញការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋាននានា ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមា នូវហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ រួមទាំងអ្នកស្លាប់ និងរបួស ដោយត្រូវចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់ តាមផែនការយុទ្ធនាការរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងផែនការសកម្មភាពរបស់អនុគណៈកម្មការទី២ នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

- ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ នៅទីប្រជុំជន តំបន់ផ្សារ នៅលើដងផ្លូវ និងតាមចិញ្ចើមផ្លូវ ដើម្បីសម្រួលដល់ការធ្វើដំណើរទៅមករបស់អ្នកប្រើប្រាស់ផ្លូវ និងជាពិសេសរួមចំណែកដល់ការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ដែលបណ្តាលមកពីគ្មានសណ្តាប់ធ្នាប់សាធារណៈ។

## ៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង៖

- ចាត់វិធានការឱ្យបានជាអតិបរមាដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់អំពើអនាចារ អំពើរំលោភសេពសន្ថវៈ ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ អំពើហិង្សាក្នុងគ្រួសារដើម្បីការពារសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋឱ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ដោយអនុវត្តឱ្យបានហ្មត់ចត់តាមច្បាប់ និងផែនការយុទ្ធសាស្ត្រជាតិរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

- ត្រូវចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់ និងជាប្រចាំ តាមស្មារតីនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ និងផែនការ សកម្មភាពរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធដល់វិធានការក្នុងការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង។

## ៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព៖

- ពង្រឹងការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទនៅមូលដ្ឋាន នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ព្រមទាំងពង្រឹងសមត្ថភាព និងបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ សំដៅលើកកម្ពស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមយន្តការផ្សះផ្សា ឬសម្របសម្រួលដែលកំណត់ដោយក្រសួងយុត្តិធម៌។

- ខិតខំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ ជាពិសេសភាគីវិវាទ ឱ្យយល់អំពីខ្លឹមសារ និងសារសំខាន់នៃយន្តការ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងគោលដៅកាត់បន្ថយការកកស្ទះសំណុំរឿងនៅស្ថាប័នតុលាការ ការខាតបង់ពេលវេលា ថវិកាផ្ទាល់ខ្លួននិងការចំណាយថវិការដ្ឋ ព្រមទាំងបង្កើតភាពសុខដុមរមនាក្នុងសង្គម។

## ៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ៖

- មានវិធានការក្នុងការគ្រប់គ្រង ថែរក្សា និងការពារធនធានធម្មជាតិ និងបរិស្ថាន អនាម័យក្នុងភូមិ ឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព ជាពិសេសយន្តការដោះស្រាយបញ្ហាសំរាម សំណល់រឹង និងសំណល់រាវ សំដៅធ្វើឱ្យភូមិ ឃុំ សង្កាត់ មានសោភ័ណភាព គ្មានសំរាម ធ្វើឱ្យការរស់នៅប្រកបដោយផាសុកភាព មានភាពថ្លៃថ្នូរ ស៊ីវិល័យ និងមានអនាគតរុងរឿង ផ្អែកតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ។

- បញ្ជ្រាបការអប់រំដល់ប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានា ស្តីពីកិច្ចការពារថែរក្សាបរិស្ថាន រួមទាំងវិធីសាស្ត្រនៃការរក្សាសុខភាព ការចូលរួមថែរក្សាអនាម័យ សុវត្ថិភាពចំណីអាហារ ឧទាហរណ៍៖ ការផលិតស្រាខុសបទដ្ឋានបច្ចេកទេស ការចែកចាយ លក់ដូរ និងប្រើប្រាស់ថ្នាំពេទ្យ គ្រឿងសម្អាង... ក្លែងក្លាយ ឬអត់គុណភាព។

៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព៖

- រួមគ្នាចាត់វិធានការឆ្លើយតប និងផ្តល់ព័ត៌មានត្រឡប់ឱ្យបានទាន់ពេលវេលា ក្នុងការកាត់បន្ថយនូវហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានាដែលកើតមានឡើងនៅក្នុងមូលដ្ឋាន ឧទាហរណ៍៖ ជំងឺកូវីដ-១៩...។

- ត្រូវបំផុសចលនាមហាជនដើម្បីចូលរួមនៅក្នុងការបង្ការ ទប់ស្កាត់ ការពារជំងឺឆ្លងរាតត្បាតកាចសាហាវ និងគ្រោះមហន្តរាយដែលបាននិងបម្រុងកើតឡើងជាយថាហេតុ។

III. ផែនការសកម្មភាព

១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព និងតម្លាភាពទទួលបានជំនឿទុកចិត្ត៖

- យកចិត្តទុកដាក់លើកកម្ពស់ក្នុងការផ្តល់សេវាសាធារណៈចាំបាច់ និងជាមូលដ្ឋាន រួមមាន ការអប់រំ សុខាភិបាល ផ្លូវគមនាគមន៍ ទឹកស្អាត អគ្គិសនី និងសេវាសាធារណៈចាំបាច់ដទៃទៀតដែលពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងសមធម៌។

- ពង្រឹង និងពង្រីកការអនុវត្តតួនាទីរបស់ការិយាល័យច្រកចេញ-ចូលតែមួយ និងយន្តការច្រកចេញ-ចូលតែមួយ លើការងារផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរថែមទៀត។ រៀបចំឱ្យមានអ្នកទទួលខុសត្រូវច្បាស់លាស់ក្នុងការប្រចាំការដោះស្រាយការស្នើសុំសេវានានារបស់ប្រជាពលរដ្ឋ ឱ្យបានទាន់ពេលវេលា ឆាប់រហ័ស មានប្រសិទ្ធភាព និងតម្លាភាព។

២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ៖

- ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ បញ្ជាដឹកនាំការអនុវត្តផែនការប្រយុទ្ធប្រឆាំងបទល្មើសពិសេស អំពើលួច ឆក់ ប្លន់ ចាប់ជំរិតទារប្រាក់នៅតាមភូមិ ឃុំ សង្កាត់។

- លើកកម្ពស់គុណភាព និងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ សំដៅបង្កើនប្រសិទ្ធភាពក្នុងការស្រាវជ្រាវស៊ើបអង្កេត ព្រមទាំងជំរុញសកម្មភាពតាមចាប់មុខសញ្ញា និងអនុវត្តដីកាដែលសេសសល់ ។

- តាមដាន ត្រួតពិនិត្យ និងដឹកនាំតម្រង់ទិសដល់នគរបាលប៉ុស្តិ៍រដ្ឋបាល ក្នុងការអនុវត្តការងារតាមបែបនគរបាលនិងសហគមន៍។

- យកចិត្តទុកដាក់គាំទ្រដល់ប៉ុស្តិ៍នគរបាលរដ្ឋបាល ទាំងស្មារតី សម្ភារ ការពង្រឹងសមត្ថភាព ដើម្បីមានលទ្ធភាពក្នុងការគ្រប់គ្រងស្ថានការណ៍សន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់។

- ពង្រឹងប្រជាការពារ ដើម្បីចូលរួមក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន និងលើកកម្ពស់កិច្ចសហការជាមួយកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើតឱ្យមានយន្តការផ្លាស់ប្តូរព័ត៌មាន និងគាំទ្រគ្នាទៅវិញទៅមក ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

- រៀបចំផែនការបង្ការ ទប់ស្កាត់ បង្ក្រាប សកម្មភាពលួចនាំសារធាតុញៀនខុសច្បាប់គ្រប់ប្រភេទ តាមច្រកព្រំដែន និងច្រករបៀងនៃប្រទេសជិតខាងចូលមកកម្ពុជា និងការរក្សាទុក ឬលួចកែច្នៃសារធាតុញៀនសំយោគគ្រប់ប្រភេទ។

- ជំរុញសកម្មភាពក្នុងការអនុវត្តវិធានការរដ្ឋបាលស្របជាមួយនឹងវិធានការច្បាប់ ក្នុងការស្រាវជ្រាវតាមដាន ត្រួតពិនិត្យ ការលួចជួញដូរ និងប្រើប្រាស់សារធាតុញៀននៅតាមទីតាំងសប្បាយដ្ឋាននានា និងនៅតាមភូមិ ឃុំ សង្កាត់។

- ជំរុញការផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ តាមសាលារៀន និងបញ្ជ្រាបការអប់រំនៅតាមពិធីផ្សេងៗដែលប្រារព្ធធ្វើឡើងនៅតាមមូលដ្ឋាន អំពីគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន។

- ខិតខំស្រាវជ្រាវ និងបង្ក្រាបឱ្យបានការលួចដាំដុះដំណាំដែលមានសារធាតុញៀននៅគ្រប់ភូមិសាស្ត្រ។

- បង្កើនការផ្លាស់ប្តូរព័ត៌មានជាមួយដៃគូជាតិ អន្តរជាតិ សំដៅម្ចាស់ការក្នុងការបង្ការ ទប់ស្កាត់ពីចម្ងាយ និងសហការស្រាវជ្រាវកាត់ផ្តាច់ខ្សែរយៈ និងជាពិសេសតាមចាប់មេខ្លោងមកផ្តន្ទាទោសតាមច្បាប់។

### ៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍៖

- បង្កើនការអប់រំ ផ្សព្វផ្សាយអំពីច្បាប់ និងផលប៉ះពាល់នានាដែលបណ្តាលមកពីការមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដោយត្រូវមានវិធីសាស្ត្រផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព មានជាអាទិ៍ កម្មវិធីសាសនា សិល្បៈ កម្មវិធីអភិវឌ្ឍន៍ វេទិកាសាធារណៈ និងកម្មវិធីផ្សេងៗក្នុងសង្គម។

- រៀបចំសណ្តាប់ធ្នាប់ឱ្យបានល្អនៅតំបន់មានផ្សារ ទីប្រជុំជន សាលារៀន និងតំបន់ស្មុគស្មាញនានា ត្រូវហាមឃាត់ការដាក់តាំងលក់ទំនិញនៅលើដងផ្លូវ ការចតយានយន្តគ្រប់ប្រភេទដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរ។ ចំពោះទីតាំងធ្វើអាជីវកម្ម សេវាកម្ម ត្រូវរៀបចំឱ្យមានចំណតសម្រាប់មធ្យោបាយនិងយានយន្តគ្រប់ប្រភេទ ដើម្បីបញ្ចៀសនូវការកកស្ទះចរាចរណ៍ និងការបាត់បង់សណ្តាប់ធ្នាប់។ ត្រូវមានវិធានការរៀបចំសណ្តាប់ធ្នាប់ និងការឆ្លងកាត់ផ្លូវរបស់សិស្សានុសិស្សពេលម៉ោងចេញ-ចូលសាលារៀន។

### ៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង៖

- បង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ទាំងបច្ចេកទេសប្រតិបត្តិការ និងនីតិវិធីក្នុងការស្រាវជ្រាវ ស៊ើបអង្កេតប្រយុទ្ធប្រឆាំងអំពើអនាចារ ការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ។

- ខិតខំជំរុញសកម្មភាពស្រាវជ្រាវ ស៊ើបអង្កេតរកមេខ្លោងពាក់ព័ន្ធដល់អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ ព្រមទាំងសកម្មភាពជួញដូរតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប។

- សហការជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជំរុញសកម្មភាពផ្សព្វផ្សាយអប់រំការជួយសង្គ្រោះ និងស្តារនីតិសម្បទាដល់ជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

- ពង្រឹងការគ្រប់គ្រង និងស្រាវជ្រាវតាមទីតាំងអាជីវកម្ម សេវាកម្មដែលលួចប្រព្រឹត្តអំពើអនាចារ និងការជួញដូរផ្លូវភេទ។

- ពង្រឹងយន្តការសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ ក្នុងការផ្លាស់ប្តូរព័ត៌មាននានា ពាក់ព័ន្ធដល់សភាពការណ៍ បណ្តាញឧក្រិដ្ឋជន ព្រមទាំងព័ត៌មានដទៃផ្សេងទៀត ពាក់ព័ន្ធដល់ជនរងគ្រោះនៅក្រៅប្រទេស។

- មានកម្មវិធីច្បាស់លាស់ក្នុងការរៀបចំវេទិកាផ្សព្វផ្សាយអប់រំអំពីគុណធម៌ សីលធម៌ វប្បធម៌ និងច្បាប់ពាក់ព័ន្ធ សំដៅកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសកម្មភាពក្មេងទំនើងនៅតាមភូមិ ឃុំ សង្កាត់។

**៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព**

- ខិតខំបង្កើនសមត្ថភាព ចំណេះដឹង និងជំនាញបន្ថែមទៀតដល់អ្នកទទួលសិទ្ធិក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទទួលបាននូវយន្តការផ្សេងៗដែលសមស្របទៅនឹងវិធានច្បាប់ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ កាន់តែទទួលបាននូវជំនឿទុកចិត្តពីប្រជាពលរដ្ឋ។

- ត្រូវខិតខំពង្រឹងអព្យាក្រឹតភាព វិជ្ជាជីវៈរបស់អ្នកសម្របសម្រួល ឱ្យប្រកាន់ខ្ជាប់នូវភាពមិនលំអៀងរក្សាការសម្ងាត់ ដើម្បីបង្កើនភាពជឿជាក់ដល់ភាគីវិវាទ។

- អ្នកសម្របសម្រួល ត្រូវធ្វើកំណត់ហេតុនៃការដោះស្រាយ និងជូនព័ត៌មានអំពីលទ្ធផលនៃដំណោះស្រាយរបស់គូវិវាទ ដែលទទួលយកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការឱ្យបានលឿន និងចំណេញពេលវេលា ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅបានជ្រាប។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ**

- បង្កើនការតាមដាន ត្រួតពិនិត្យនៅតាមទីតាំងសាធារណៈ អំពីការគ្រប់គ្រងអនាម័យ បរិស្ថាន ឈរលើគោលការណ៍ «ការរស់នៅស្អាត ភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ អនាគតរុងរឿង»។

- ទប់ស្កាត់ និងឆ្លើយតបឱ្យបានទាន់ពេលវេលានូវគ្រោះថ្នាក់ដែលបណ្តាលមកពីការពុលចំណីអាហារ និងភេសជ្ជៈនានា ជាពិសេសត្រូវមានការត្រួតពិនិត្យតាំងពីដើមទី ទាំងការនាំចូល ការដាំដុះ និងការផលិត។

- មានផែនការបង្ការ ទប់ស្កាត់ឱ្យបានទាន់ពេលវេលា នូវសកម្មភាពលួចកាប់បំផ្លាញ និងទន្ទ្រានទីតាំងព្រៃឈើនៅក្នុងសហគមន៍ និងសហការជាមួយឧទ្យានុរក្សដើម្បីបង្ការ និងទប់ស្កាត់ការកាប់ទន្ទ្រាននៅតាមតំបន់ការពារធម្មជាតិ។

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតអាចសាហាវប្រកបដោយប្រសិទ្ធភាព**

មានផែនការម្ចាស់ការទុកជាមុនក្នុងការសង្គ្រោះបឋមជួយដល់អាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានា។ ត្រូវអប់រំអំពីវិធីការពារ ទប់ស្កាត់ជំងឺឆ្លងរាតត្បាតដែលមានហានិភ័យខ្ពស់ វិធីបង្ការគ្រោះថ្នាក់បណ្តាលមកពីគ្រោះមហន្តរាយ តាមវិធានការនានាដែលកំណត់ដោយក្រសួងជំនាញ។

## IV. **ការចាត់តាំងអនុវត្ត**

១. ក្រសួងមហាផ្ទៃធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលដោយត្រូវ៖

- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងដឹកនាំតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- បង្កើតលេខាធិការដ្ឋានដើម្បីរៀបចំផែនការសកម្មភាព និងតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿន ក្នុងការអនុវត្តលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងបូកសរុប វាយតម្លៃ រាយការណ៍តាមដំណាក់កាលនីមួយៗ ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការចាត់តាំងអនុវត្តគោលនយោបាយនេះ។

២. ក្រសួង ស្ថាប័ននានាចំណុះរាជរដ្ឋាភិបាល ត្រូវរៀបចំក្រុមការងារដើម្បីជួយក្នុងការរៀបចំផែនការសកម្មភាព និងជួយតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿនក្នុងការអនុវត្តលក្ខណសម្បត្តិ នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលមានការពាក់ព័ន្ធទៅនឹងវិស័យជំនាញរបស់ក្រសួង ស្ថាប័ននីមួយៗ និងត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃតាមកាលកំណត់។

៣. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមឱ្យបានសកម្ម គាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ឱ្យទទួលបានជោគជ័យ។

៤. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងទទួលខុសត្រូវដឹកនាំផ្ទាល់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវ៖

- រៀបចំលេខាធិការដ្ឋានដោយមានអង្គភាពនគរបាលធ្វើជាសេនាធិការ និងមានសមាសភាពមកពីមន្ទីរ អង្គភាពពាក់ព័ន្ធនានា ព្រមទាំងរៀបចំឱ្យមានក្រុមការងារចុះជួយតាមមូលដ្ឋានឃុំ សង្កាត់ ដោយយកភូមិជាគោលដៅ ដើម្បីសហការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។
- ជំរុញការផ្សព្វផ្សាយ និងបំផុសចលនាមហាជន ព្រមទាំងផ្នែកពាក់ព័ន្ធ ដើម្បីសហការ និងចូលរួមគាំទ្រ ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- រដ្ឋបាលឃុំ សង្កាត់ត្រូវដាក់បញ្ចូលការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិល ព្រមទាំងក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីជួយគាំទ្រ និងជំរុញការអនុវត្តឱ្យទទួលបានជោគជ័យ។

៥. នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីស្នូលក្នុងការចាត់ចែងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវ៖

- អនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវតួនាទី ភារកិច្ច និងតាមទម្រង់នៃការងារនគរបាលនិងសហគមន៍
- ដឹកនាំពង្រឹងកម្លាំងប្រជាការពារ និងធ្វើការផ្សព្វផ្សាយបំផុសចលនាមហាជន រួមទាំងផ្នែកពាក់ព័ន្ធ ដើម្បីចូលរួមក្នុងចលនាអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។
- ត្រូវមានកិច្ចសហការ ទំនាក់ទំនងជាមួយកងកម្លាំងសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឱ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសគ្រប់ប្រភេទ ការរៀបចំអនាម័យ បរិស្ថាន កាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីជំងឺឆ្លងរាតត្បាតកាចសាហាវ និងគ្រោះមហន្តរាយនានាក្នុងភូមិ ឃុំ សង្កាត់។

៦. វេទិកាសាធារណៈ និងការផ្សព្វផ្សាយ៖

ត្រូវរៀបចំឱ្យមានវេទិកាសាធារណៈ និងវេទិកាផ្សព្វផ្សាយអំពីគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដើម្បីបញ្ជ្រាបការយល់ដឹង និងបំផុសឱ្យមានការសហការ ចូលរួមគាំទ្រពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋនៅទូទាំងប្រទេស៖

- ការរៀបចំវេទិកាសាធារណៈ គួរខិតខំរៀបចំឱ្យបានញឹកញាប់តាមរូបភាពតូចៗ យ៉ាងហោចណាស់ក្នុង០១ខែ ឱ្យបានម្តង ដោយក្នុងវេទិកានេះ ត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធទៅនឹងលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងត្រូវខិតខំដោះស្រាយរាល់បញ្ហាប្រឈមនានាដែលបានលើកឡើង ព្រមទាំងផ្តល់ព័ត៌មានឆ្លើយតបឱ្យបានសមស្របជូនប្រជាពលរដ្ឋវិញ។ ក្នុងករណីដោះស្រាយមិនបាន ត្រូវរាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីមានវិធានការដោះស្រាយបន្ត។
- ការផ្សព្វផ្សាយគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» គួររៀបចំឱ្យបានញឹកញាប់តាមរូបភាពតូចៗជាក់ស្តែងទៅតាមភូមិសាស្ត្រនីមួយៗ សំដៅផ្សព្វផ្សាយចំគោលដៅ មុខសញ្ញា និងបង្កលក្ខណៈដល់អ្នកចូលរួមមានឱកាសបំពេញមុខរបរផង និងអាចទទួលបានការផ្សព្វផ្សាយដោយផ្ទាល់ផងដែរ។

៧. ការប្រឡងប្រណាំង៖

ត្រូវចាត់តាំងឱ្យមានចលនាប្រឡងប្រណាំងបង្កើតស្នាដៃប្រចាំឆ្នាំនីមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញកាតព្វកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្ត គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ។

៨. គ្រប់ក្រសួង ស្ថាប័ន និងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ត្រូវចាត់តាំងប្រជុំបូកសរុប រយៈពេលយ៉ាងយូរ០៦ខែម្តង ដើម្បីមានមូលដ្ឋានក្នុងការវាយតម្លៃ ដកពិសោធន៍ និងដាក់ចេញទិសដៅអនុវត្តបន្ត។

ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

៩. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃអង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

១០.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានការគិតគូរគ្រោងថវិកាសម្រាប់អនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងគោលនយោយបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» នៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗ។

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានយកទៅផ្សព្វផ្សាយទូលំទូលាយទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋដើម្បីយល់ជ្រួតជ្រាប និងចូលរួមគាំទ្រអនុវត្តប្រកបដោយជោគជ័យ។

ថ្ងៃ អង្គារ ១៣ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សម្តេច ឯកឧត្តម លោកជំទាវប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
-គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អាជ្ញាធរ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ក្រោមជាតិ
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ